# ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
# សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ភាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ របស់អគ្គនាយកដ្ឋានពន្ធដារ
TAX PAYMENT OBLIGATIONS OF OWNERS OF ALL TYPES OF VENICLES OF THE GENERAL DEPARTMENT OF TAXATION

ជំនាញ: សវនកម្ម

រៀបរៀងដោយ៖ ហេង សេងហ៊័រ
អត្តលេខ: MVI20/015

ឆ្នាំសិក្សា ៖ ឆ្នាំ២០២៣ - ២០២៥

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ភាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ
# របស់អគ្គនាយកដ្ឋានពន្ធដារ

TAX PAYMENT OBLIGATIONS OF OWNERS OF ALL TYPES OF VENICLES OF THE GENERAL DEPARTMENT OF TAXATION

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម

លោកគ្រូណែនាំ ៖ បេក្ខបណ្ឌិត យ៉ែម សុខហៀក

ឆ្នាំសិក្សា ៖ ឆ្នាំ២០២៣ - ២០២៥

# គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២០
# ប្រធានបទ៖ ភាគព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទរបស់អគ្គនាយកដ្ឋានពន្ធដារ

| | |
|---|---|
| លោកគ្រូណែនាំ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បណ្ឌិត កង ឱម |
| សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ | នាយកមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត ហ៊ូ គុជគន្ធលីនណា | បណ្ឌិត សេង សំអឿន |

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

# ឧទ្ទិសស្នាដៃ

នាងខ្ញុំឈ្មោះ **ហេង សេងហ័រ** ជាបេក្ខជនបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ **សវនកម្ម** ជំនាន់ទី២០ នៃសាកលវិទ្យាល័យវ៉ាន់ដា

សូមឧទ្ទិសស្នាដៃ នៃការស្រាវជ្រាវនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធវីរព្រះមហាក្សត្រខ្មែរ គ្រប់សម័យកាល ដែលព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ច ដើម្បីបុព្វហេតុជាតិនិងមាតុភូមិ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធមេដឹកនាំខ្មែរគ្រប់សម័យកាល ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ ប្រជាជន និងទឹកដី។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី កុលបុត្រ កុលធីតា និងជនរួមជាតិខ្មែរគ្រប់រូប ពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្ម នៅគ្រប់ សម័យកាល ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋរបស់យើងទាំងអស់គ្នា។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបាន លះបង់ ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។

សូមឱ្យមាតុភូមិកម្ពុជា ស្ថិតនៅគង់វង្ស មានភាពរុងរឿងសម្បូរសប្បាយ មានភាពថ្លៃថ្នូរ និងថ្កុំថ្កើងតរៀងទៅ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញ សវនកម្ម នៅសាកលវិទ្យាល័យវ៉ាន់ដាអស់រយៈពេល២ឆ្នាំសិក្សារួចមក នាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់សម្រាប់តម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរ ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន សាកលវិទ្យាល័យក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី២ ដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបានជាពិសេសនោះ គឺមុខវិជ្ជាពន្ធដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹង ដើម្បីរៀបចំ និងកាន់កាប់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង និងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។ ដោយនាងខ្ញុំយល់ថាចំណេះដឹងខាងពន្ធដារ ជាចំណេះដឹងបន្ថែមមួយដ៏មានសារៈសំខាន់សម្រាប់សវនកម្មទាំងអស់ធ្វើការសិក្សាស្វែងយល់ និងស្របពេលដែលនាងខ្ញុំមានឱកាសបានរៀបចំរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះ ទើបខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទរបស់អគ្គនាយកដ្ឋានពន្ធដារ»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀត យល់កាន់តែច្បាស់ពីពន្ធដារ។ ខ្ញុំសង្ឃឹមថាការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀតដែលមានបំណងលើការសិក្សាពីវិស័យពន្ធ។

ជាទីបញ្ចប់នាងខ្ញុំ សូមមេត្តាខន្តីអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូ រាមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំក៏រីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពល្អប្រសើរ។

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្ម នៃសាកលវិទ្យាល័យវ៉ាន់ដា។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្ដល់នូវការលើកទឹកចិត្ត អនុគ្រោះដល់នាងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត ភឹង ឱម** និងលោកគ្រូ **យ៉េម សុខហៀក** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់នាងខ្ញុំឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់នាងខ្ញុំ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

នាងខ្ញុំសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់នាងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២.......

**ហត្ថលេខា**

ថ្ងៃ..................ខែ................ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦.....

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២.......

**គ្រូណែនាំ**

# សេចក្តីសង្ខេប នៃការស្រាវជ្រាវ

បច្ចុប្បន្នមានការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ច និងមានស្ថេរភាពនយោបាយដូច្នេះទំហំអ្នកប្រកបអាជីវកម្មក៏មានការកើនឡើង ហើយអគ្គនាយកដ្ឋានពន្ធដារក៏បានរៀបចំនៅវិធីសាស្ត្រជាច្រើនដើម្បីគ្រប់គ្រង និងប្រមូលចំណូលពន្ធឱ្យមានប្រសិទ្ធភាព ហើយផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានឆាប់រហ័ស។ ពន្ធតែមប្រ៏គឺជាប្រភេទពន្ធមួយដែលបានរួមចំណែកក្នុងការប្រមូលចំណូល ហើយចំណូលទាំងនេះគឺយកទៅបើកប្រាក់បៀវត្សដល់មន្ត្រីរាជការ ទាហាន ធ្វើផ្លូវ ស្ពាន មន្ទីរពេទ្យ សាលារៀនជាដើម ដើម្បីជួយក្នុងការអភិវឌ្ឍប្រទេសឱ្យបានឆាប់រហ័សផងដែរ។

ដើម្បីឱ្យការប្រកាសពន្ធ មានលក្ខណៈត្រឹមត្រូវ មិនមានកំហុសដែលធ្វើឱ្យមានការផាកពិន័យផ្សេងៗ ទើបនាងខ្ញុំលើកយកនូវនីតិវិធីក្នុងការអនុវត្តពន្ធតែមប្រ៏សារពើពន្ធ និងការបំពេញលិខិតប្រកាសពន្ធតែមប្រ៏សារពើពន្ធជាឧទាហរណ៍ក្នុងការបំពេញនូវតារាងស្ថិតិ ˝ស្លាកអាជីកម្មដ្ឋាន˝ និងតារាងស្ថិតិ˝ផ្ទាំងផ្សាយពាណិជ្ជកម្ម˝ ដោយភ្ជាប់ជាមួយនឹងផ្ទាំងរូបភាពជាងស្តែងនៃស្លាក ដែលមានខ្នាតគិតជាដេស៊ីម៉ែត ការគណនាប្រាក់ពន្ធ ការបំពេញទម្រង់បង់ប្រាក់ពន្ធ មកបង្ហាញ។

សរុបសេចក្តីមកការប្រកាសពន្ធ មានលក្ខណៈត្រឹមត្រូវ មិនមានកំហុសដែលធ្វើឱ្យមានការផាកពិន័យផ្សេងៗ យើងត្រូវទៅជួបនិងមន្ត្រីជំនាញនៅ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ នៅអគារលេខ៩២F ផ្លូវសហព័ន្ធរុស្សីកៀ្សរ អគ្គនាយកដ្ឋានពន្ធដារ ដែលជាកន្លែងទទួលលិខិតប្រកាសពន្ធតែមប្រ៏សារពើពន្ធ លើស្លាកអាជីកម្មដ្ឋាន ឬផ្ទាំងផ្សាយពាណិជ្ជកម្ម។ បើមន្ត្រីជំនាញពិនិត្យរួចហើយមិនមានបញ្ហាអ្វីទេ នោះយើងអាចបង់ប្រាក់ពន្ធនៅធនាគារដែលពាក់ព័ន្ធបានតាមលេខគណនីធនាគារនីមួយៗ រួចទើបមកប្រកាសពន្ធនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញវិញ។

## Research Summary

Currently, there is rapid economic growth and political stability, so the number of business operators has also increased. The General Department of Taxation has also prepared many methods to manage and collect tax revenue effectively and provide services to taxpayers quickly. Stamp duty is a type of tax that contributes to revenue collection, and these revenues are used to pay salaries to civil servants, soldiers, build roads, bridges, hospitals, schools, etc. to help develop the country quickly.

In order for the tax declaration to be accurate and free from errors that lead to various penalties, I will present the procedures for applying stamp duty and filling out the stamp duty declaration form, for example, filling out the "Business Sign" and "Advertising Sign" tables, along with a sample poster of the sign with dimensions in decimeters, calculating the tax amount, and filling out the tax payment form.

In conclusion, if the tax declaration is correct and there are no errors that will result in fines, we must go to meet with a specialist officer at the Phnom Penh Tax Office at Building 92F, Russian Federation Street, near the General Department of Taxation, which is where you can receive tax declaration letters and tax stamps on business signs or advertising boards. If the specialist officer checks and finds no problems, we can pay the tax at the relevant bank according to each bank account number and then return to declare the tax at the Phnom Penh Tax Office.

# មាតិកា


ទំព័រ

ឧទ្ទិសស្នាដៃ ........ i

អារម្ភកថា ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

Research Summary ........ vi

## ជំពូកទី១: សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២: រំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅនៃកាតព្វកិច្ច ........ ៤

២.១.១ និយមន័យកាតព្វកិច្ច ........ ៤

២.១.២ ប្រភេទនៃកាតព្វកិច្ច ........ ៤

២.១.៣ ប្រភពនៃកាតព្វកិច្ច ........ ៥

២.២ នីតិវិធីដើម្បីឱ្យម្ចាស់យានជំនិះទទួលបានសិទ្ធិប្រើប្រាស់ឯកសារបង់ពន្ធ ........ ៦

២.២.១ និយមន័យនីតិ ........ ៦-៧

២.២.២ ប្រភេទនៃនីតិ ........ ៨-៩

២.៣ ការកំណត់ប្រភេទយានជំនិះដែលត្រូវជាប់ពន្ធ ........ ១០

២.៣.១ និយមន័យពន្ធ ........ ១០

២.៣.២ ប្រវត្តិនៃពន្ធ ........ ១១

២.៣.៣ ប្រភេទនៃពន្ធ ........ ១២

២.៣.៤ ច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពបន្ធដារ ........ ១២-១៥

## ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ. .......... ១៦
៣.១.១ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ .......... ១៦
៣.១.២ បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ .......... ១៧
៣.១.៣ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ .......... ១៨
៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ .......... ១៨
៣.១.៥ អង្គការលេខ .......... ១៩
៣.២ នីតិវិធីដែលអគ្គនាយកដ្ឋានពន្ធដារ ឱ្យម្ចាស់យានជំនិះគ្រប់ប្រភេទ ទទួលបានសិទ្ធិប្រើប្រាស់ឯកសារបង់ពន្ធ .......... ១៩
៣.២.១ កាតព្វកិច្ចរបស់ម្ចាស់យានជំនិះ .......... ១៩
៣.២.២ កាតព្វកិច្ចភ្នាក់ងារពន្ធដារ .......... ២០
៣.២.៣ សិទ្ធទទួល និងការប្រើប្រាស់ឯកសារពន្ធ .......... ២១
៣.២.៤ ទោសទណ្ឌ ការខកខានមិនបានបង់ពន្ធ និងបញ្ហាប្រឈម .......... ២១
៣.២.៥ ការប្រកាសពន្ធ .......... ២២
៣.៣ ប្រភេទយានជំនិះដែលអគ្គនាយកដ្ឋានពន្ធដារ កំណត់ឱ្យជាប់ពន្ធ .......... ២៣-២៥

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង .......... ២៦
៤.២ ការវិភាគលើចំណុចខ្សោយ .......... ២៦

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន .......... ២៧
៥.២ ការផ្តល់អនុសាសន៍ .......... ២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើសកលលោក ការបង់ពន្ធបានកើតឡើងយូរណាស់មកហើយ ដោយផ្តើមចេញពីគោលនយោបាយ និងគោលការណ៍នៃកិច្ចព្រមព្រៀងគ្នាក្នុងការបង់ពន្ធនៅក្នុងឆ្នាំ១២១៨ នារជ្ជកាលរបស់ព្រះមហាក្សត្រ Jeam Sans Terre ប្រទេសអង់គ្លេស។ ចំណែកឯប្រទេសកម្ពុជា បន្ទាប់ពីបញ្ចប់សង្គ្រាម បានធ្វើការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សារសេរី ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើអាជីវកម្ម។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការអភិវឌ្ឍន៍ប្រទេសជាតិយ៉ាងល្អប្រសើរ ក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ ជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណជាង៧% និងកំណើតយ៉ាងគំហុកនៃការប្រមូលពន្ធបានដល់២៥%ក្នុងឆ្នាំ២០១៥។ ការរីកចម្រើននេះមិនអាចកាត់ផ្តាច់ចេញពីតួនាទីដ៏សំខាន់របស់វិស័យឯកជនបានឡើយ។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលកម្ពុជា បានធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយដើម្បីធ្វើឱ្យការធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជាកាន់តែប្រសើរឡើង តាមរយៈការរៀបចំបច្ចេកវិទ្យាក្នុងការស្វែងរកឈ្មោះពាណិជ្ជកម្មដែលមានលក្ខណៈសាមញ្ញ ដើម្បីជួយសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម និងការធ្វើឱ្យនីតិវិធីសារពើពន្ធកាន់តែមានប្រសិទ្ធភាពឡើង។ ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៥ បានលុបចោលនៅពន្ធរបបម៉ៅការជំនួសដោយពន្ធរបបពិត (ជាធម្មតាសំដៅលើរបបស្វ័យប្រកាស)។ ជាការពិតកំណែទម្រង់នេះបានលើកទឹកចិត្តដល់ក្រុមហ៊ុននានាឱ្យអនុវត្តតាមច្បាប់កាន់តែច្រើន ប៉ុន្តែវាក៏បានបង្កើតនូវការយល់ច្រឡំមួយចំនួន ដោយសារតែកង្វះខាតនូវព័ត៌មាន និងការយល់ដឹងអំពីនីតិវិធីសារពើពន្ធ។

ដើម្បីធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពទាំងនេះ ក្នុងគោលដៅកែប្រែកម្ពុជាឱ្យទៅជាប្រទេសមានចំណូលជាមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក៏ដូចជាដើម្បីធានាស្ថិរភាព និងចីរភាពថវិកាសម្រាប់បម្រើការនៃចំណាយសាធារណៈចាំបាច់នានា ដូចជាការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងគ្រប់វិស័យ ការបណ្តុះបណ្តាលជំនាញដល់យុវជន និងយុវនារី ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវសំណាញ់សុវត្ថិភាពសង្គម និងពង្រឹងគុណភាពសេវាសាធារណៈ។ ដោយមើលឃើញពីចំណុចសំខាន់ៗដែលបានរៀបរាប់ខាងលើ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទមួយ ស្តីពី **«កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទនៅអគ្គនាយកដ្ឋានពន្ធដារ»** យកមកធ្វើការស្រាវជ្រាវ និងរៀបចំជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការបង់ពន្ធមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចជាតិ ព្រោះវាបានចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានលទ្ធភាពយកទៅចំណាយ ដោយមិនចាំបាច់បោះប័ណ្ណបំណុលដែលអាចបង្កឱ្យមានបញ្ហាអតិផរណា និងមួយផ្នែកទៀតដើម្បីឈានទៅការបញ្ឈប់ជំនួយពីបរទេស។

ហេតុដូច្នេះទើបនាងខ្ញុំមានសំណួរមួយចំនួនចោទសួរដូចខាងក្រោម៖

១. តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីដូចម្ដេច ដើម្បីឱ្យម្ចាស់យានជំនិះគ្រប់ប្រភេទទទួលបានសិទ្ធិប្រើប្រាស់ឯកសារបង់ពន្ធ?

២. តើអគ្គនាយកដ្ឋានពន្ធដារ បានធ្វើការកំណត់ពីប្រភេទនៃយានជំនិះដូចម្ដេចដែលត្រូវជាប់ពន្ធ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញពីយន្តការនៃកាតព្វកិច្ចបង់ពន្ធ ដោយផ្ដោតទៅលើ៖

☞ ប្រវត្តិនៃអគ្គនាយដ្ឋានពន្ធដារនៅកម្ពុជា

☞ គោលនយោបាយ បេសកកម្ម និងទស្សនវិស័យរបស់ពន្ធដារ

☞ តួនាទី និងភារកិច្ចរបស់អគ្គនាយដ្ឋានពន្ធដារ...។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើ «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទនៅអគ្គនាយកដ្ឋានពន្ធដារ**» នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្តីពីសារពើពន្ធ ពន្ធត្រូវបានបង្កើតឡើងយូរណាស់មកហើយ ហើយដោយមានពេលវេលាកំណត់ ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបនាងខ្ញុំធ្វើការស្រាវជ្រាវតែក្នុងឆ្នាំ២០២៣ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការសរសេររបាយការណ៍ទៅលើប្រធានបទស្តីពី «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទនៅអគ្គនាយកដ្ឋានពន្ធដារ**» ឱ្យបានជោគជ័យនាងខ្ញុំធ្វើការស្រាវជ្រាវដូចខាងក្រោម៖

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង គឺជាការប្រមូលទិន្នន័យតាមរយៈការចុះសួរដោយផ្ទាល់ពីមន្ត្រី និងអ្នកគ្រប់គ្រងនៃអគ្គនាយកដ្ឋានពន្ធដារ។ ដោយឯកសារដែលនាងខ្ញុំប្រមូលបានត្រូវរៀបចំតាមលំដាប់លំដោយជាផ្នែកៗ ទៅតាមខ្លឹមសារអត្ថន័យនៃឯកសារនីមួយៗដោយឡែកៗពីគ្នា ដើម្បីងាយស្រួលក្នុងការសរសេរកិច្ចការស្រាវជ្រាវឱ្យកាន់តែប្រសើរឡើង។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺប្រមូលទិន្នន័យតាមរយៈការស្រាវជ្រាវនៅបណ្ណាល័យនានា និក្ខេបបទរៀមច្បង និងតាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារជាដើម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនៅភាពរីកចម្រើនដល់និស្សិតជាច្រើន ក្នុងការផ្លាស់ប្តូរពួកគេឱ្យយល់ដឹងពីសកម្មភាពក្នុងសង្គម ការទំនាក់ទំនងនិងប្រត្តិបត្តិការមួយចំនួននៅក្នុងពេលបច្ចុប្បន្ននេះ។ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺផ្តល់នូវចំណេះដឹងដល់នាងខ្ញុំដូចជា៖

- មានការទំនាក់ទំនងការប្រាស្រ័យទាក់ទងគ្នា និងការចូលរួមក្នុងសង្គម

- មានបទពិសោធន៍ក្នុងការបង្ហាត់បង្រៀន ក្នុងការដោះស្រាយបញ្ហានានា
- បង្កើនចំណេះដឹងបន្ថែម ទៅលើការសិក្សាស្រាវជ្រាវ ក៏ដូចជាការសិក្សា
- ធ្វើឱ្យនិស្សិតជាច្រើនមើលឃើញពីគុណតម្លៃនៃការសិក្សាស្រាវជ្រាវផ្សេងៗ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើងដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់ នៅចំណុចនីមួយៗនិងបានធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំនឹងដែលកំណត់នៃការស្រាវជ្រាវ សារសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន និង អនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមក នាងខ្ញុំ ក៏បានបែងចែកជា៥ជំពូកដែលរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖ (សេក្តីផ្តើម)** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមាន ការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖ (រំលឹកទ្រឹស្តី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ នឹង ទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ (លទ្ធផលនៃការស្រាវជ្រាវ)** បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ គោលនយោបាយ ទស្សនវិស័យ និងបេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ។

**ជំពូកទី៤៖ (ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ)** វិភាគនឹងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖ (សេក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)** សន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# ទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី២
# ភាតព្វកិច្ចនៃការបង់ពន្ធ

## ២.១ លក្ខណៈទូទៅនៃភាតព្វកិច្ច

### ២.១.១ និយមន័យភាតព្វកិច្ច

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត[1]។

កាតព្វកិច្ច គឺសំដៅលើកិច្ចការរបស់ពលរដ្ឋត្រូវតែធ្វើវាជាចាំបាច់ ដែលមិនអាចរំលងបានឡើយ[2]។

កាតព្វកិច្ច គឺជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា(កូនបំណុល) មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ថា(ម្ចាស់បំណុល)[3]។

### ២.១.២ ប្រភពនៃភាតព្វកិច្ច

កាតព្វកិច្ចត្រូវបានផ្តល់និយមន័យថាជាទំនាក់ទំនងគតិយុត្តិដែលចងបុគ្គលពីរនាក់ គឺភាគីដែលមានករណីយកិច្ចជា "កូនបំណុល"ទៅលើភាគីម្ខាងទៀតជា "ម្ចាស់បំណុល" ដែលទទួលបានប្រយោជន៍ពីករណីយកិច្ចនោះ។

តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ កាតព្វកិច្ចមានប្រភពសំខាន់ពីរ គឺប្រភពក្នុងធន្ទៈ សំដៅលើកាតព្វកិច្ចដែលកើតឡើងពីធន្ទៈ ដែលមានបំណងបង្កើតចំណងអានុភាពគតិយុត្តិ និងបើគ្មានបំណងចង់បង្កើតចំណងអានុភាពគតិយុត្តិទេ ច្បាប់ចាត់ទុកថាលក្ខណៈបែបនោះជាកាតព្វកិច្ចក្រៅធន្ទៈ។ ក្រមនេះបានបែងចែកយ៉ាងច្បាស់ថា ប្រភពកាតព្វកិច្ចក្នុងធន្ទៈភាគីរួមមានពីរ គឺកិច្ចសន្យា និងកិច្ចឯកតោភាគី។ ចំណែកប្រភពកាតព្វកិច្ចក្រៅធន្ទៈ គឺរួមមានការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចម្រើនឥតហេតុ អំពើអនីត្យានុកូល និងដោយបញ្ញត្តិរបស់ច្បាប់។

ផ្អែកតាមក្រមរដ្ឋប្បវេណីជាមូលដ្ឋាន ប្រភពនីមួយៗនៃកាតព្វកិច្ចសុទ្ធតែត្រូវបានបកស្រាយនិយមន័យដែលរួមមាន៖

កិច្ចសន្យា (មាត្រា៣១១)៖ កិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ មានធន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ ជាក់ស្តែងក្នុងគន្ថីទី៥នៃក្រមរដ្ឋប្បវេណីនៃជំពូកទី១ ដល់ជំពូកទី១២ មានរៀបរាប់ប្រភេទកិច្ចសន្យាពិសេសចំនួន១៣។

កិច្ចឯកតោភាគី(មាត្រា៣១២)៖ កិរិយានៃការបង្កើតកែប្រែឬរំលត់កាតព្វកិច្ចដោយឯកឯង ឬថាដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។ អច្ច័យទាន ការទទួលស្គាល់កូន ការរំលាយកិច្ចសន្យា ក៏ដូចជាការលុបចោលកិច្ចសន្យា សុទ្ធតែជាសកម្មភាពឯកតោភាគី។

ភាពខុសគ្នាយ៉ាងចម្បងរវាងកិច្ចសន្យា និងកិច្ចឯកតោភាគី គឺកិច្ចសន្យាតម្រូវឱ្យមានការព្រមព្រៀងរវាងគូភាគី តែសកម្មផាពឯកតោភាគី មិនតម្រូវឱ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតនោះទេ។

ការគ្រប់គ្រងដោយឈឺឆ្អាល(ស្មារតីមាត្រា៧២៩)៖ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ឬការជ្រៀតជ្រែកចូលកិច្ចការអ្នកដទៃ តាមរយៈការជួយគ្នាទៅវិញទៅមក ដោយគ្មានសិទ្ធិអំណាច។

---

[1] https://www.facebook.com/604655766258239/posts/980081385382340/
[2] https://thmeythmey.com/m/?page=detail&id=72846
[3] lawyers (2019-12-23 15:54) ដូចម្តេចដែលហៅថាកាតព្វកិច្ច? https://www.khsearch.com/qna/27677

អ្នកគ្រប់គ្រងឈឺឆ្អាល តាមពិតទៅគ្មានសិទ្ធិតែគ្រប់គ្រងកិច្ចការអ្នកដទៃដើម្បីអ្នកដទៃនោះ ហើយសាមីខ្លួនដំបូងឡើយមិនដឹង។ ការគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើឡើងដោយសុចរិត និងត្រូវថ្លឹងថ្លែងធន្ទៈរបស់សាមីខ្លួនឱ្យសមរម្យ។ អ្នកគ្រប់គ្រងដោយឈឺឆ្អាលមានករណីក្នុងការជូនដំណឹង រាយការណ៍ប្រគល់ប្រាក់ ឬផលឱ្យសាមីខ្លួន ពេលដែលសាមីខ្លួនឆ្លើយតបអាចបន្តឬបញ្ឈប់ក្នុងការគ្រប់គ្រង។

សេចក្ដីចម្រើនឥតហេតុ(ស្មារតីមាត្រា៧៣៦)៖ ការទទួលបានផលប្រយោជន៍ដោយ សារទ្រព្យសម្បត្តិ ឬកម្លាំងពលកម្មរបស់អ្នកដទៃដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយការទទួលបានផលប្រយោជន៍នោះធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍របស់អ្នកដទៃ។

បើភាគីដែលបានប្រយោជន៍ជាជនសុចរិត គឺនឹងសងទៅភាគីម្ខាងទៀតត្រឹមប្រយោជន៍នៅមានតែបើភាគីម្ខាងទៀតជាជនទុច្ចរិត ដឹងខ្លួនថាបានចម្រើនដោយឥតហេតុគឺត្រូវសងប្រយោជន៍ដោយបានដឹងរួមនឹងការប្រាក់។

អំពើអនីត្យានុកូល (មាត្រា៧៤២)៖ អំពើបំពានសិទ្ធិនិងប្រយោជន៍អ្នកដទៃដែលបង្កើតឱ្យមានកាតព្វកិច្ចនៃការទទួលខុសត្រូវសំណងរដ្ឋប្បវេណីអាចជាទ្រព្យសម្បត្តិ ឬពុំជាទ្រព្យសម្បត្តិតាមរយៈការពិចារណាលើហេតុនិងផល។

ការទទួលខុសត្រូវគឺត្រូវផ្អែកទៅលើភាពគ្រោះថ្នាក់ និងផលប្រយោជន៍ ហើយការទទួលខុសត្រូវត្រូវបែងចែកជាបីប្រភេទធំៗ គឺការទទួលខុសត្រូវចំពោះអំពើខ្លួនឯង ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ ការទទួលខុសត្រូវចំពោះអំពើរបស់សត្វ និងវត្ថុ។

កាតព្វកិច្ចកើតមានឡើងដោយមូលហេតុដូចខាងក្រោមនេះ៖

- ដោយកិច្ចសន្យា
- ដោយសកម្មភាពឯកតោភាគី
- ដោយការគ្រប់គ្រងដោយឈឺឆ្អាល
- ដោយសេចក្ដីចម្រើនដោយឥតហេតុ
- ដោយអំពើអនីត្យានុកូល និង
- ដោយបញ្ញត្តិនៃច្បាប់[4]។

### ២.១.៣ ប្រភពនៃកាតព្វកិច្ច

#### ក.រដ្ឋធម្មនុញ្ញ

- តាមន័យចង្អៀត គឺជាច្បាប់កំពូលរបស់ជាតិ
- តាមន័យទូទៅ ជាច្បាប់ដែលចែងអំពីការបែងចែកអំណាច ស្ថាប័ននយោបាយរបបនយោបាយ សិទ្ធិសេរីភាពរបស់បុគ្គល និងប្រជាមតិ។
- រដ្ឋធម្មនុញ្ញរឹង ជាប្រភេទរដ្ឋធម្មនុញ្ញដែលមិនងាយនឹងធ្វើវិសោធនកម្ម

ឧទាហរណ៍ ៖ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ត្រូវបានហាមឃាត់ក្នុងការធ្វើវិសោធនកម្ម។

- រដ្ឋធម្មញ្ញារឹង ជាប្រភេទរដ្ឋធម្មនុញ្ញ ដែលងាយនឹងធ្វើវិសោធនកម្ម

ឧទាហរណ៍៖ រដ្ឋធម្មនុញ្ញនៃបញ្ញនតាប្រទេស Common Law

[4] https://www.facebook.com/116208229766750/posts/449067973147439/

### ខ.សន្ធិសញ្ញា

គឺជាការព្រមព្រៀងរបស់គូភាគី ឬពហុភាគី ឧទាហរណ៍ រដ្ឋ និងរដ្ឋ រដ្ឋ និងអង្គការ រដ្ឋ និង ក្រុមហ៊ុនសាជីវកម្ម ហើយមានអនុភាពគតិយុត្តិចំពោះគូភាគី និងពហុភាគី ដែលគេហៅថាចំណងគតិយុត្តិ។

ការផ្តល់សច្ចាប័ន សន្ធិសញ្ញាគឺជានីតិវិធីរដ្ឋបាលមួយ ដែលផ្តល់សិទ្ធិទៅឱ្យសភាក្នុងការ អនុម័តយល់ព្រម ដើម្បីធ្វើឱ្យសន្ធិសញ្ញានេះ អាចយកទៅអនុវត្តបាននៅក្នុងវិធាន ការផ្ទៃ ក្នុង។ ចំពោះតំលៃគតិយុត្តិនៃសន្ធិសញ្ញាអាចស្មើ ៖

- រដ្ឋធម្មនុញ្ញ៖ រាល់សន្ធិសញ្ញាទាំងឡាយ ដែលមានចែងក្នុងមាត្រាណាមួយ ឬជំពូកណាមួយនៃរដ្ឋធម្មនុញ្ញសន្ធិសញ្ញានោះមានតម្លៃគតិយុត្តិស្មើនឹងរដ្ឋធម្មនុញ្ញ ដូច្នេះច្បាប់ទាំងឡាយក៏ត្រូវគោរពសន្ធិសញ្ញាដូចរដ្ឋធម្មនុញ្ញដែរ។ ចំពោះការត្រួតពិនិត្យធម្មនុញ្ញភាព អនុវត្តចំពោះសន្ធិសញ្ញាដែលមានតំលៃគតិយុត្តិស្មើច្បាប់ និងច្បាប់ដទៃទៀត។
- ច្បាប់៖ រាល់សន្ធិសញ្ញាទាំងឡាយណា ដែលត្រូវបានរៀបចំចេញជាសេចក្តីព្រាងច្បាប់ ហើយអនុម័តដោយសភា និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនោះ មានតម្លៃសន្ធិសញ្ញាស្មើច្បាប់ និងច្បាប់ផ្សេងៗ ដែរ។

## ២.២ នីតិវិធីដើម្បីឱ្យម្ចាស់យានជំនិះទទួលបានសិទ្ធប្រើប្រាស់ឯកសារបង់ពន្ធ

### ២.២.១ និយមន័យនីតិ

នីតិ គឺជាបណ្តុំវិធានគតិយុត្តទាំងឡាយ ដែលមានគោលដៅធ្វើឱ្យសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម[5]។

នីតិ គឺជាសំណុំឯកសារនៃវិធានគតិយុត្តទាំងឡាយណា ដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការគ្រប់គ្រងឱ្យមានសណ្តាប់ធ្នាប់របស់សង្គម និងមានរបៀបរៀបរយល្អប្រសើរ[6]។

នៅសម័យអង្គរប្រទេសកម្ពុជាពុំទាន់មានច្បាប់ទេ អ្វីគឺអាស្រ័យលើការសម្រេចលើព្រះមហាក្សត្រ។ ព្រះមហាក្សត្រ គឺជាចៅក្រម ឬអាជ្ញាកណ្តាលដ៏កំពូលក្នុងការដោះស្រាវិវាទជូនប្រជារាស្ត្រ។ ព្រះមហាក្សត្ររៀបចំជំនួបទទួលប្រជារាស្ត្រក្នុងសវនាការ។ អ្នកចូលរួមថ្វាយយោបល់មានឥស្សរៈជនជាន់ខ្ពស់ប្រចាំព្រះរាជវាំង ឬនៅពេលខ្លះ គឺប្រជាកសិករតូចតាច។ សម័យនោះច្បាប់ឬបទបញ្ញត្តិផ្សេងៗ ត្រូវបានភ្នាក់ងាររាជការដើរស្រែកប្រកូកប្រកាស ឬចារនៅលើផ្ទាំងសិលា ហើយដាក់តាំងផ្សព្វផ្សាយ នៅតាមច្រកចេញចូលនៅតាមទីកន្លែងសក្ការៈដូចជា ប្រាសាទ ឬក្លោងទ្វារ ព្រះបរមរាជវាំងជាដើម ហើយដើម្បីរក្សានូវបទបញ្ញត្តិទាំងនោះ ក៏មានការចារឹកនៅលើស្បែកសត្វ និងលាបនឹងខ្មុកម្សៅក្យ័ណ៍។ល។

ក្រោយសម័យអង្គរ ច្បាប់ទម្លាប់ត្រូវបានបង្កើតឡើងបន្តិចម្តងៗជាបន្តបន្ទាប់។ សិលាចារឹកបានបង្ហាញថា ប្រជារាស្ត្រត្រូវតែគោរពវិធានផ្សេងៗដែលបានកំណត់ ការមិនគោរពនឹងបណ្តាលឱ្យមានការដាក់ទណ្ឌកម្មដែលធានាដោយអាជ្ញាធរសាធារណៈ។

នៅក្នុងគ្រឹស្តសករាជ៦២០ ក្នុងរាជ្ជកាលព្រះបាទជ័យជេដ្ឋា ច្បាប់ខ្មែរក៏ត្រូវបានរៀបរៀង ដែលបន្ទាប់មកមានការកែរលំអរនិងពិនិត្យឡើងវិញ ក្នុងរជ្ជកាលព្រះបាទអង្គឌួង (១៨៤៧-១៨៦០)។ គេសង្កេត

[5] https://www.facebook.com/1902207923220708/posts/3462494920525326/
[6] https://www.tnaot.com/km/m/detail/article/2127308

ឃើញថាច្បាប់ទាំងនោះត្រូវបានទទួលឥទ្ធិពលយើងខ្លាំងពីព្រះពុទ្ធសាសនា។ ក្រោយមក ប្រព័ន្ធច្បាប់ខ្មែរត្រូវបានផ្លាស់ប្តូរនៅក្រោយដែលកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំង ពិសេសនៅក្រោយឆ្នាំ ១៩១០។

នៅសម័យកាលបច្ចុប្បន្នគេអាចចាត់បញ្ចូលប្រព័ន្ធច្បាប់ចម្បងៗ នៅលើពិភពលោកដូចតទៅៈ

**១.ប្រព័ន្ធច្បាប់ស៊ីវិល**

ប្រព័ន្ធច្បាប់ស៊ីវិលមានដើមកំណើតនៅអឺរ៉ុកណ្តាល បន្ទាប់មកបានផ្សព្វផ្សាយទៅក្រៅទ្វីប តាមរយៈការដាក់អាណានិគម។ បណ្តាប្រទេសដែលធ្លាប់នៅក្រោមអានិគម អេស្បាញ ប៉ុទុយហ្គេ បារាំង ឬហូឡង់ គឺសុទ្ធតែកាន់ប្រព័ន្ធច្បាប់ស៊ីវិលទាំងអស់។ នៅអាស៊ីប្រទេសដែលមានប្រវត្តិធ្លាប់ប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលមានជាអាទិ៍ដូចជា ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ថៃ កម្ពុជា វៀតណាម ឡាវ។ល។ ប្រព័ន្ធច្បាប់ស៊ីវិលបានចាប់បដិសន្ធិទាំងស្រុងពី ៤៥០B.C មុសគ្រឹស្តសករាជ្យ ហើយបានរីករាលដាលពេញពិភពលោក។

បច្ចុប្បន្នរដ្ឋខ្លះនៃប្រទេសដែលប្រព័ន្ធច្បាប់ common law ដូចជាសហរដ្ឋអាមេរិកមានរដ្ឋមួយ ប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលគឺរដ្ឋ **Louisiana** និងកោះ Puerto Rico ដែលស្ថិតនៅចម្ងាយ ១៥០០គ.ម ពីរដ្ឋ Florida។ នៅប្រទេសកាណាដាក៏ជាប្រទេសកាន់ប្រព័ន្ធច្បាប់ common law ប៉ុន្តែរដ្ឋ **Quebec** កាន់ប្រព័ន្ធច្បាប់ស៊ីវិល។

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលចៅក្រមគ្មានតួនាទីបង្កើតច្បាប់ទេ គឺគ្រាន់តែជាអ្នកអនុវត្តច្បាប់ និងបកស្រាយច្បាប់ប៉ុណ្ណោះ។ ប្រព័ន្ធច្បាប់ស៊ីវិលគឺជាប្រព័ន្ធច្បាប់ដែលផ្អែកលើច្បាប់សរសេរ ឬក្រុង ដែលមានមូលដ្ឋានពីច្បាប់ Roman។ នៅសតវត្សទី១៨ មានប្រទេសលើពិភពលោកចំនួន៦០ ដែលច្បាប់របស់គេទទួលឥទ្ធិពលពីក្រមនៃច្បាប់ Roman។ បច្ចុប្បន្នប្រទេសមួយចំនួនបានក្លាយជា ប្រទេសដែលកាន់ប្រព័ន្ធច្បាប់កូនកាត់ ដូចជាប្រទេស អេស្ស៊ីបដែលប្រព័ន្ធច្បាប់របស់គេបានទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់របស់បារាំង អង់គ្លេសផង ហើយក៏ទទួលឥទ្ធិពលខ្លះពីច្បាប់ឥស្លាម។

ប្រទេសកម្ពុជាបច្ចុប្បន្នជាប្រទេសកាន់ប្រព័ន្ធច្បាប់ស៊ីវិល តែដោយសារការវិវត្តន៍ខ្លួនកន្លងមក ឆ្លងកាត់នូវតំណាក់កាលលំបាក និងមនោគមវិជ្ជាខុសៗគ្នា ដូចជាសម័យមុនឆ្នាំ១៩៧៥ ក្រោយឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ និងក្រោយឆ្នាំ១៩៧៩ ដល់ ១៩៩៨ ក៏ទទួលឥទ្ធិពលខ្លះពីប្រព័ន្ធច្បាប់ ផ្សេងៗ។

**២.ប្រព័ន្ធច្បាប់ common law**

ប្រព័ន្ធច្បាប់នេះ ចាប់បដិសន្ធិនៅក្រោយកំណើតនៃព្រះយេស៊ូគ្រីសចំនួន១០៦៦ឆ្នាំ(១០៦៦ AD) នៅចក្រក្រភពអង់គ្លេស ហើយដែលមានប្រភពសំខាន់ចេញពីសកម្មភាពរបស់ព្រះរាជសាលាយុត្តិធម៌។

ប្រព័ន្ធច្បាប់ common law រួមមាននីតិអង់គ្លេស និងនីតិរបស់ប្រទេសភាគច្រើន ដែលនិយាយភាសាអង់គ្លេស ជាពិសេសបណ្តាប្រទេសដែលជាសមាជិកនៃសមាគម common wealth ហើយដែលគេស្គាល់ប្រព័ន្ធច្បាប់នេះថាជាប្រព័ន្ធច្បាប់អង់គ្លេស-អាមេរិក។

របៀបដែលប្រព័ន្ធច្បាប់នេះប្រកាន់យកគឺ ការបង្កើតវិធានតាមរឿងក្តីនីមួយៗ។ តុលាការធ្វើការសិក្សាទៅលើករណីជាក់ស្តែងនីមួយៗ និងចេញសេចក្តីសម្រេចទៅតាមករណីជាក់ស្តែងនោះ ហើយត្រូវគេយកទៅអនុវត្តសម្រាប់ដោះស្រាយរឿងក្តីក្រោយៗទៀត បង្កើតបានជាយុទ្ធសាស្រ្ត សម្រាប់កាត់ក្តីក្រោយៗទៀត។ នៅក្នុងប្រព័ន្ធច្បាប់ common law គេទទួលស្គាល់ថា ចៅក្រមមិនគ្រាន់ តែជាអ្នកបកស្រាយទេ តែថែមទាំងជាអ្នកបង្កើតច្បាប់ទៀត។

ប្រទេសដែលកាន់ប្រព័នច្បាប់ common law មានដូចជា អង់គ្លេស អាមេរិក អៀរឡង់ កាណាដា អូស្រ្តាលី ញ៉ូសីលែន និងបណ្តាប្រទេសមួយចំនួនដែលជាសមាជិកសមាគម common wealth។

**៣.ប្រព័ន្ធច្បាប់សង្គមនិយម**

ប្រព័ន្ធច្បាប់នេះ បានចាប់កំណើតបន្ទាប់ពីជ័យជំនះនៃបដិវត្តន៍ខែតុលា១៩១៧ នៅប្រទេសរុស្ស៊ី។ គឺជាបដិវត្តន៍ដើម្បីលុបបំបាត់នូវរបបកម្មសិទ្ធិឯកជន ដោយធ្វើជាតិតូនីយកម្ម និងសមូហភាព រូបនីយកម្មលើដីធ្លី រោងចក្រ សហគ្រាស និង មធ្យោបាយផលិតកម្មផ្សេងៗ។

លិទ្ធិសង្គមនិយមចាត់ទុកប្រព័ន្ធច្បាប់ទាំងអស់ដែលមានកន្លងមក ជាឧបករណ៍បម្រើឱ្យរបបកម្មសិទ្ធិឯកជនដែលជារបបសក្តិភូមិមានការជិះជាន់និងកេងប្រវ័ញ្ច។ ដើម្បីលុបបំបាត់របបនេះគេត្រូវកំទេចចោលនូវរបបកម្មសិទ្ធិឯកជន ហើយជំនួសមកវិញនូវរបបកម្មសិទ្ធិសមូហភាព និងកម្មសិទ្ធិរដ្ឋ។

នៅឆ្នាំ១៩៨៥ក្រោមការដឹកនាំរបស់លោក Gor Batchev នៅសាធារណៈសង្គមនិយមសហភាពសូវៀត (សសសស) បានចាប់ផ្តើមធ្វើកំណែទម្រង់មួយឈ្មោះ Perestroika។ នៅឆ្នាំ១៩៩០ ក្រោមកំណែទម្រង់នេះ បានធ្វើការកំណត់សមភាពរវាងកម្មសិទ្ធិ៣យ៉ាងគឺ កម្មសិទ្ធិឯកជន កម្មសិទ្ធិ សមូហភាព និងកម្មសិទ្ធិរដ្ឋ តាមរយៈវិសោធនកម្មរដ្ឋធម្មនុញ្ញ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩០ សាធារណៈសង្គមនិយមសហភាពសូវៀត(សសសស) ត្រូវបានបញ្ចប់ ហើយបណ្តាប្រទេសនៅអឺរ៉ុបប្រទេសខាងកើត និងរដ្ឋមួយចំនួនរបស់សាធារណៈសង្គមនិយមសហភាពសូវៀត (សសសស) បានទាមទារឯករាជ្យ។ បច្ចុប្បន្នគេឃើញមាននៅសល់ប្រទេស ខ្លះដូចជាប្រទេសចិន ដែលនៅបន្តតាមលទ្ធិសង្គមនិយមរបស់ខ្លួនដែលបានចាប់ផ្តើមតាំងពីបដិវត្តន៍ ១៩៦០មក។ ចាប់ពីឆ្នាំ១៩៧៨ ប្រទេសចិនបានធ្វើការកែទម្រង់ជាបណ្តើរៗតាមគោលការណ៍នៃសេដ្ឋកិច្ចទីផ្សារដើម្បីងាយស្រួលដល់វិនិយោគទុនបរទេស។ រដ្ឋធម្មនុញ្ញថ្មីឆ្នាំ ១៩៨២ របស់ប្រទេសចិន បានបង្ហាញពីការធ្វើសំយោគរវាងលិទ្ធិកុម្មុយនីស្ត និងបច្ចេកទេសច្បាប់ពីបស្ចឹមប្រទេស។

**៤.ប្រព័ន្ធច្បាប់ឥស្លាម**

គឺជាប្រព័ន្ធច្បាប់ដែលយកសាសនាជាមូលដ្ឋាន។ ប្រព័ន្ធច្បាប់នេះកំណត់ថាសង្គមដែលបរិសុទ្ធ គឺសង្គមដែលយកសាសនាជាគ្រឹះ មិនមែនសង្គមដែលយកច្បាប់ជាគ្រឹះទេ ព្រោះច្បាប់មនុស្សជាអ្នកសរសេរដូច្នេះមិនអាចបរិសុទ្ធដូចធម៌របស់ព្រះឡើយ។ គម្ពីរសាសនាដ៏ពិសិដ្ឋរបស់អ្នកកាន់សាសនាអ៊ីស្លាមឈ្មោះ កូរ៉ាន់ (Koran) ដែលចាត់ទុកជាប្រភពនៃច្បាប់ ហើយដែលគ្របដណ្តប់លើច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់រដ្ឋធម្មនុញ្ញ និងកំណត់អំពីសកម្មភាពនៃជីវិតរបស់អ្នកកាន់សាសនានេះ។ ការបកស្រាយគម្ពីរ Koran បានទាញចេញជាច្បាប់របស់ឥស្លាម ហើយឈ្មោះថា Sharia។ ប្រទេសដែលប្រើប្រព័ន្ធច្បាប់ឥស្លាមគឺបណ្តាប្រទេសនៅមជ្ឈឹមបូព៌ាដែលមានប្រហែល២៥ ប្រទេស[7]។

**២.២.២ ប្រភេទនៃនីតិ**

យោងតាមឯកសារស្រាវជ្រាវ នីតិត្រូវបានបែងចែកជាចំនួន២ប្រភេទមានខាងក្រោមនេះ៖

**១.នីតិជាតិ ៖** ជានីតិមួយដែលត្រូវបានបែងចែកជាចំនួន២ប្រភេទគឺ៖ នីតិឯកជន និងនីតិសាធារណៈ

[7] http://l1b2.weebly.com/6047608160216016609860316072603760986031607860406035607260316071.html

- **នីតិឯកជន៖** ជាវិធានទាំងឡាយសំដៅជានាការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល រវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន។ បន្ថែមពីនេះ នីតិឯកជនត្រូវបានចែកចេញជាចំនួន៥ធំៗ ដែលមានដូចជា៖
  - ✓ នីតិរដ្ឋប្បវេណី(នីតិរួម)
  - ✓ នីតីពាណិជ្ជកម្ម(នីតិពិសេស)
  - ✓ នីតិការងារ(នីតិពិសេស)
  - ✓ នីតិនិរភ័យ(នីតិពិសេស)
  - ✓ នីតិព្រហ្មទណ្ឌ(នីតិចំរុះ)។
- **នីតិសាធារណៈ៖** ជាវិធានទាំងឡាយណា ដែលមាននៅក្នុងរដ្ឋមួយសំដៅការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការ ស្ថាប័នសាធារណៈ ព្រមទាំងសម្រាប់ការគ្រប់គ្រងទំនាក់ទំនងរវាងអង្គការរដ្ឋ និងបុគ្គលិករដ្ឋជាមួយនឹងពលរដ្ឋរបស់ខ្លួន។ បន្ថែមពីនេះនីតីសាធារណៈត្រូវបានបែងចែកជាចំនួន៤ធំៗ ដែលមានដូចជា ៖
  - ✓ នីតិរដ្ឋធម្មនុញ្ញ
  - ✓ នីតិរដ្ឋបាល
  - ✓ នីតិហិរញ្ញវត្ថុ
  - ✓ នីតិព្រហ្មទណ្ឌ(និតិចម្រុះ) ។

**២. នីតិអន្តរជាតិ ឬនីតិអន្តររដ្ឋ៖** ជានីតិមួយដែលកើតឡើងដោយសង្គមអន្តរជាតិ ហើយឥតមានអង្គការនីតិបញ្ញត្តិណាចេញច្បាប់មកអនុវត្តទេ គឺចេញពី«ឆន្ទៈរបស់រដ្ឋ»តែប៉ុណ្ណោះ។ បន្ថែមពីនេះនីតិអន្តរជាតិ ឬនីតិអន្តររដ្ឋ ត្រូវបានបែងចែកជាវិធានការធំៗចំនួន២ប្រភេទគឺ៖ នីតិអន្តរជាតិសាធារណៈ និងនីតិអន្តរជាតិឯកជន ឬនីតិរួម។

- **នីតិអន្តរជាតិសាធារណៈ៖** ជាបណ្តុំនៃវិធានគតិយុត្ត ដែលគ្រប់គ្រងទៅលើទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ។ បន្ថែមពីនេះនីតិអន្តរជាតិសាធារណៈ ត្រូវបានបែងចែកជាសន្ធិសញ្ញាអន្តរជាតិជាលក្ខណៈការព្រមព្រៀងគ្នាធំៗចំនួន៤ធំៗ ដែលមានដូចជា៖
  - ✓ សន្ធិសញ្ញា នៃការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ
  - ✓ សន្ធិសញ្ញា នៃការព្រមព្រៀងរវាងរដ្ឋ និងក្រុមហ៊ុន
  - ✓ សន្ធិសញ្ញា នៃការព្រមព្រៀងរវាងរដ្ឋ និងអង្គការឥតមែនរដ្ឋាភិបាល
  - ✓ សន្ធិសញ្ញា នៃការព្រមព្រៀងរវាងរដ្ឋ និងសារជីវកម្មអន្តរជាតិ ។
- **នីតិអន្តរជាតិឯកជន ឬនីតិរួម៖** ជាវិធាននៃការគ្រប់គ្រងទំនាក់ទំនងបុគ្គលឯកជន និងបុគ្គលឯកជន ដែលគេប្រើប្រាស់សម្រាប់បំពេញបន្ថែមទៅលើភាពខ្វះចន្លោះនៃវិធានក្នុងនីតិពិសេស ខណៈនៅពេលដែលវិធានវិសេសនោះឥតមានគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហា។ បន្ថែមពីនេះនីតិអន្តរជាតិឯកជន ឬនីតិរួមត្រូវបានបែងចែកជាចំនួន៤ធំៗ ដែលមានដូចជា ៖
  - ✓ នីតិការងារមានការទំនាក់ទំនងជាបុគ្គលរវាងនឹងនិយោជិត និងនិយោជិត, កម្មករ និងថៅកែ
  - ✓ នីតិពាណិជ្ជកម្មមានការទំនាក់ទំនងការងារពាណិជ្ជកម្មរវាងបុគ្គល និងបុគ្គល

- ✓ នីតិសាធារណៈផ្សំឡើង ដោយជាតុរបស់រដ្ឋ និងសកម្មភាពរបស់រដ្ឋ
- ✓ នីតិសាធារណៈផ្សំឡើងវិធានគតិយុត្តិ ដែលគ្រប់គ្រងលើការទំនាក់ទំនងរាជការ និងរាជការ និងការទំនាក់ទំនងរាជការ និងប្រជានុរាស្ត្រ ។ បន្ទាប់មក វិធានគតិយុត្តិ ដែលគ្រប់គ្រងលើការទំនាក់ទំនងរាជការ និងប្រជានុរាស្ត្រត្រូវបានចែកចេញជាវិធានការចំនួន២ធំៗគឺៈ អ្នកស្នើសុំសេវា និងអ្នកផ្តល់សេវា[8]។

## ២.៣ ការកំណត់ប្រភេទយានជំនិះដែលត្រូវជាប់ពន្ធ

### ២.៣.១ និយមន័យពន្ធ

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។ យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ១៩៩៧ ពន្ធសំដៅដល់ពន្ធផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ (Taxpayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធ ដោយប្រយោល (មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ)។ ការប្រមូលពន្ធនេះ គឺជាការយកតាមតម្លៃ ទំនិញ ឬសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ[9]។

**ពន្ធ** គឺជាប្រាក់ដែលយើងប្រមូលក្នុងនាមរដ្ឋាភិបាល[10]។

**ពន្ធ** គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ ដើម្បីប្រមូលចំណូល មួយផ្នែកពីការគ្រប់សមាសភាពសេដ្ឋកិច្ច មានដូចជាក្រុមហ៊ុន សហគ្រាស អាជីវកម្ម និងប្រជាពលរដ្ឋ ដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

**ពន្ធ** គឺជារូបជាតុនៃការប្រមូលចំណូល ដែលផ្សាភ្ជាប់ជាមួយនឹងសិទ្ធិអំណាច នយោបាយរបស់រដ្ឋាភិបាលដែលក្រិត្យច្បាប់ជាកំណត់។

**ពន្ធ** គឺជាការបង់វិភាគទាន នូវកាតព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវ័ន្តបុគ្គល និងនីតិបុគ្គល ជូនរាជរដ្ឋាភិបាលដែលមានច្បាប់កំណត់[11]។

**ពន្ធ** គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋាភិបាល សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ[12]។

**ពន្ធ** មានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលនយោបាយប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម សេវាកម្មដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវ ចំពោះមុខច្បាប់ក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល។

---

8 *(អត្ថបទ ៖ តុលា)*

9 BizKhmer (08 Oct 2019 12:10:00) តើពន្ធគឺជាអ្វី? https://www.bizkhmer.com/articles/41290

10 https://www.ato.gov.au/General/Other-languages/In-detail/Khmer/Tax-and-super-in-Australia---what-you-need-to-know---Khmer/?page=2

11 រៀបរៀងដោយសាស្ត្រាចារ្យ វ៉ែន ឈុនហួត

12 https://www.ynn.com.kh/61357.html

**ពន្ធ** បានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលដែលបានប្រមូល។ ផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងនៅឯកភាពគ្នាអំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយនិងផលប្រយោជន៍របស់ក្រុមហ៊ុនសេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ចទីផ្សារ ដែលសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចំបាច់ ជាទូទៅពន្ធដារបានចាត់ទុកជាឧបករណ៍ហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ[13]។

**២.៣.២ ប្រវត្តិនៃពន្ធ**

ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣ បន្ទាប់មកប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម(របបខ្មែរក្រហមនិងរបបប៉ុលពត) ហើយបានធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើននាក់។ ប្រព័ន្ធពន្ធដារបានបង្កើតឡើងវិញនូវដំណាក់កាលដំបូងនៅឆ្នាំ១៩៨០ ដោយបានអនុវត្តន៍នៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីយកមកអនុវត្តន៍ និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទៈ គឺរបបពិត របបម៉ោការ និងរបបបំព្រួញ ក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយដាច់ដោយឡែក។ ដែលជាវិធាន និងជានីតិវិធីដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុងរបបកំណត់ណាមួយនោះ ត្រូវកំណត់ដោយផ្អែកទៅលើទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត(ស្វ័យប្រកាស)តែមួយប៉ុណ្ណោះ។

ការអនុវត្ត និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។

ទ្រង់ទ្រាយគតិយុត្តិមានន័យថា រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីកម្មប្រភេទអ្វី ឬមានកម្រិតផលរបរប្រចាំឆ្នាំប៉ុន្មានក៏ ដោយ។ សហគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជនដែលធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណេញ ឬប្រាក់ចំណូលដែលជាបេតិកភ័ណ្ឌរបស់ខ្លួន។

កម្រិតផលរបរប្រចាំឆ្នាំ គឺជាការកំណត់ពន្ធលើប្រាក់ចំណេញតាមរបបពិតដែលត្រូវអនុវត្តន៍ ហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី៥០០លានរៀនឡើងទៅ។ ចំណែកឯការផ្គត់ផ្គង់ចម្រុះដែលមានរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៤លានរៀន សកម្មភាពសេវាកម្មដូចជា សណ្ឋាគារ កន្លែងម៉ាស្សា រង្គសាល ភោជនីយដ្ឋាន កន្លែងកម្សាន្តនានាដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើតសកម្មភាពអណ្តូងរ៉ែ និងអាជីវកម្មនេសាទ[14]។

---

13 បណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា

14 ដកស្រង់ពីបណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា

ដើម្បីថែរក្សាផលប្រយោជន៍សាធារណៈទាំងអស់ ចាំបាច់ត្រូវទាមទារឱ្យមានការចូលរួមពីសំណាក់មហាជន។ តាមការស្រាវជ្រាវ ការកកើតពន្ធ ឬទ្រឹស្តីទាក់ទងនឹងពន្ធ ត្រូវបានគេរកឃើញថា បានកើតឡើងស្របជាមួយនឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែលមានការកើតចេញឡើង នូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស។ Evolution នៃសង្គមមនុស្សជាហេតុផលដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធ ដែលស្ថិតនៅលើរបត់មួយដ៏យូរលង់ ត្រូវបានឆ្លោះមករកភាពសាំញ៉ាំ និងពិបាកមកដល់បច្ចុប្បន្ននេះ[15]។

**២.៣.៣ ប្រភេទពន្ធ**

**ពន្ធ** គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធចំនួន១៨ ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

- ពន្ធលើប្រាក់ចំនេញ
- ប្រាក់រំដោះពន្ធលើប្រាក់ចំនេញ
- ពន្ធអប្បបរមា
- ពន្ធកាត់ទុក
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- អាករលើផលរបរ
- ពន្ធលើឈ្នួលផ្ទះ និងដី
- អាករពិសេសលើទំនិញ និងសេវាមួយចំនួន
- ពន្ធតែមប្រ៊ី
- ពន្ធប៉ាតង់
- ពន្ធប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធសត្តឃាត
- អាករស្នាក់នៅ
- អាករបំភ្លឺសាធារណៈ
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ[16]។

---

[15] ស៊ឹម សូលីន: Master of Business Administration

[16] https://www.ynn.com.kh/61357.html

**២.៣.៤ ច្បាប់និងបទបញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ**

**មាត្រាទី១០១ នៃច្បាប់ស្តីពីសារពើពន្ធ**

«បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងកំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច»។«ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងកំឡុង១៥ថ្ងៃ ក្រោយពីផ្លាស់ប្តូរឈ្មោះអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស»។

**មាត្រា៣(ថ្មី)នៃច្បាប់ស្តីពីសារពើពន្ធ**

**«នីតិបុគ្គល»** សំដៅដល់សហគ្រាស ឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ**«នីតិបុគ្គល»** រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការ សាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ«**នីតិបុគ្គល**» សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា។ ពាក្យ«**នីតិបុគ្គល**» ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនអាជីវកម្ម ឬសហគ្រាសឯកបុគ្គល។

**ប្រកាសលេខ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ**

**«សកម្មភាពសេដ្ឋកិច្ច»** សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកប្រាក់ចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

**«អាជីវកម្ម»** សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅ ទាញយកប្រាក់ចំណូលពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងៗទៀត។

**ប្រកាសលេខ០២៥ សហវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

**អ្នកជាប់ពន្ធតូច** គឺជាសហគ្រាសឯកបុគ្គល មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់៧០០លានរៀន (62,500$ -175,000$) ឬមានផលរប ឬរំពឹងថាផលរបក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦០លានរៀន (ប្រមាណ 15,000$)ឡើងទៅ។

**អ្នកជាប់ពន្ធមធ្យម** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី៧០០លានរៀល ដល់៤,០០០លានរៀន (175,00$ -1,000,000$)។

**អ្នកជាប់ពន្ធធំ** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី៤,០០០លានរៀន(1,000,000$) ឡើងទៅ។

**ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយខ្សែក**

សំណុំឯកសារភ្ជាប់ទាំងអស់ ដែលជាច្បាប់ថតចម្លង ដែលតម្រូវឱ្យភ្ជាប់សម្រាប់ការចុះបញ្ជីពន្ធដារ ត្រូវមានការបញ្ជាក់ **«ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម»** ពីមន្ត្រីពន្ធដារ មានសមត្ថកិច្ច ឬពីក្រសួងពាក់ព័ន្ធះ

- **សម្រាប់អ្នកជាប់ពន្ធតូច**

| | |
|---|---|
| ឯកសារតម្រូវ | |
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់SO1) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែរ ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៤ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំងឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| ឯកសារត្រូវភ្ជាប់បើមាន៖ | |
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច។ |

- **សម្រាប់អ្នកជាប់ពន្ធមធ្យម-ធំ**

| | |
|---|---|
| ឯកសារតម្រូវ | |
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់១០១) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ៣ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅធនាគារ ដែលចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែរ ដែលមានសុពលភាព |
| ៦ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៧ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៨ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច។ |

**បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងការការដាក់ពាក្យស្នើសុំនៅរដ្ឋបានសារពើពន្ធ**

ទម្រង់101(អ្នកជាប់ពន្ធមធ្យម-ធំ) ទម្រង់S01 (អ្នកជាប់ពន្ធតូច)[17]





[17] www.ccc-cambodia.org

ទម្រង់**អតប ១០១** គឺជាពាក្យស្នើសុំចុះបញ្ជីសម្រាប់បុគ្គលជាប់អាករ ហើយក៏អាចប្រើជាពាក្យស្នើសុំចុះបញ្ជី ដោយស្ម័គ្រចិត្តផងដែរ។ ទម្រង់នេះត្រូវបានផ្តល់ជូនលោក/លោកស្រីដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។ លោក/លោកស្រីត្រូវបំពេញទម្រង់នេះនិងផ្តល់នូវព័ត៌មានបន្ថែមនានាទៅតាមការតម្រូវ ហើយយកទម្រង់ នេះទៅដាក់ជូន នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលផលរបររបស់លោក/លោកស្រីមានការកើនឡើងលើសពីកំរិតអប្បបរមានៃផលរបរត្រូវចុះបញ្ជី។

ចំពោះក្រុមហ៊ុនដើមទុនគ្រប់ប្រភេទអ្នកនាំចេញនាំចូលសហគ្រាសវិនិយោគ ឬអង្គភាពរបស់រដ្ឋត្រូវបំពេញទម្រង់ហើយយកទៅ ដាក់ជូននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទៅមុនពេលចាប់ផ្តើមប្រកបអាជីវ កម្ម។ ចំពោះការយឺតយ៉ាវក្នុងការ ដាក់ពាក្យស្នើសុំចុះបញ្ជីលោក /លោកស្រីនឹងត្រូវទទួលរងទោសទណ្ឌទៅតាមច្បាប់ស្តីពីសារពើពន្ធ។ នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជី អគ្គនាយកដ្ឋានពន្ធដារនឹងផ្តល់ជូនលោក/លោកស្រីនូវលេខចុះបញ្ជីដែលជាលេខ អត្តសញ្ញាណកម្មអតបរបស់លោក/លោកស្រី។ វិញ្ញាបនប័ត្រចុះបញ្ជីត្រូវបានផ្តល់ជូនលោក/លោកស្រី ហើយត្រូវតាំងឬព្យួរវិញ្ញាបនប័ត្រនេះនៅទីកន្លែងអាជីវកម្ម ជាសំខាន់របស់ខ្លួន។ ប្រសិនបើការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបានបដិសេធ អគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងដល់លោក/លោកស្រីដោយភ្ជាប់ជាមួយនូវសេចក្តីពន្យល់ផ្សេងៗដែលជាហេតុផលនៃការបដិសេធ។

# ជំពូកទី៣
# ទល្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ភាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ នៅអគ្គនាយដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ




ប្រព័ន្ធពន្ធដារត្រូវលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារមានការកើតមានឡើងនៅសង្គ្រាម (របបខ្មែរក្រហម ឬរបបប៉ុលពត) និងបានធ្វើឱ្យប្រជាជនជួបនៅភាពលំបាក ការបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើ

ងវិញដំបូងនៅឆ្នាំ ១៩៨២ ដែលបានអនុវត្តឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត ដែលគេហៅថា របបម៉ៅការហើយបានគ្រប់គ្រងដោយនាយកដ្ឋានពន្ធដារ។ លើសពីនេះទៅទៀត នាយកដ្ឋាន

ពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្ត និងមានការចែកច្បាប់និងមាត្រាយ៉ាងច្បាស់លាស់។ ពន្ធទាំងនោះរួមមាន៖

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ៉យ និងបារី ដែលជាផលិតផលមកពីបរទេស។
- ពន្ធប៉ាតង់ ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីពន្ធបាតង់និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសដោយព្រះរាជក្រមលេខ១១ ន.ស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទបញ្ញត្តិស្តីពីសារពើពន្ធ។
- ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូងគឺ ចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។
- ពន្ធលើកាត់ទុក ចាប់ផ្តើមគឺចេញពីព្រះរាជក្រមលេខ នស.រកម. ០២៩៧ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។
- ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៤ ខែ ធ្នូ ១៩៩៧ ចេញដោយព្រះរាជក្រម និងអនុក្រឹត្យលេខ ៨៨ អនុក្រ.បក ថ្ងៃទី២៩ ធ្នូ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ តែអនុម័តពិតប្រាកដគឺ ថ្ងៃទី១ ខែ មករា ឆ្នាំ១៩៩៩។
- អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤ និង ៦ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា ១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម. ១២១៥/០១៦ ចុះថ្ងៃទី ១៧ ធ្នូ ២០១៥ និងប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពីការកំណត់វិធាននិងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច។

សរុបរួមប្រវត្តិរបស់អង្គភាពពន្ធដារ

-1953: ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ

-1975ដល់1079: ពន្ធដាត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត

-1980: នាយកដ្ឋានពន្ធដាររូបានបង្កើតឡើងវិញ

-2008: នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ

### ៣.១.២ បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធ រួមមានការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធ ដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាព សាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែល មានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន

**៣.១.៣ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ**

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្ទុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់ គ្រងប្រចាំឆ្នាំនីមួយៗ

### ៣.១.៣ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.៤ អង្គការលេខ

**អង្គការលេខរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**




- ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តម អ៊ុំ សីហា អគ្គនាយករង
- ឯកឧត្តម ជាប ជាវុធ អគ្គនាយករង
- ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង

- ឯកឧត្តម មិញ បានកុសល អគ្គនាយករង
- ឯកឧត្តម កែន សម្បត្តិ អគ្គនាយករង
- ឯកឧត្តម ហេង សុខណាង អគ្គនាយករង
- លោកជំទាវ ប៊ុន នារី អគ្គនាយិការង។

## ៣.២ នីតិវិធីដែលអគ្គនាយកដ្ឋានពន្ធដារ ឱ្យម្ចាស់យានជំនិះគ្រប់ប្រភេទ ទទួលបានសិទ្ធិប្រើប្រាស់ឯកសារបង់ពន្ធ

### ៣.២.១ ភារកិច្ចរបស់ម្ចាស់យានជំនិះ

ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តនៃច្បាប់ និងការទប់ស្កាត់លើចំណាយមិនចាំបាច់ក្នុងការបង់ពន្ធលើយានជំនិះគ្រប់ប្រភេទ ម្ចាស់យានជំនិះត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើយានជំនិះគ្រប់ប្រភេទសម្រាប់ប្រចាំឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឱ្យបានទាន់ពេលវេលាដែលបានកំណត់។
- ការដាក់លិខិតប្រកាសពន្ធ និងការបង់ពន្ធ៖
  - ចំពោះរថយន្ត ម្ចាស់រថយន្តត្រូវសរសេរបំពេញលិខិតដាក់ឱ្យខ្លួនឯងចំនួន០២(ពីរ) ច្បាប់ ដែលមានតម្លៃស្មើ២០០(ពីររយ)រៀល និងបង់ពន្ធតាមច្បាប់កំណត់ ដោយភ្ជាប់នូវបង្កាន់ដៃបង់ពន្ធ។
  - ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រូវទិញប័ណ្ណបង់ពន្ធដោយពុំចាំបាច់បំពេញលិខិតប្រកាសឡើយ។
- ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធដោយផ្ទាល់នៅតាមប៉ុស្តិ៍ (ទីចំណត) ឬស្នាក់ការពន្ធដារ ឬសាខាពន្ធដារ ដែលសម្រេចដោយអាជ្ញាធរដែនដីរាជធានី ខេត្ត ដើម្បីទប់ស្កាត់ការកើតឡើងនូវតម្លៃលើស ឬទិញប័ណ្ណក្លែងក្លាយ។
- ត្រូវសហការជាមួយភ្នាក់ងារពន្ធដារ ឬសមត្ថកិច្ចនានា ឬអាជ្ញាធរដែនដី ក្នុងករណីពិនិត្យឃើញមានការបង់ពន្ធលើស ឬលក់ប័ណ្ណក្លែងក្លាយ។
- ម្ចាស់យានយន្ត ឬអាជ្ញាធរដែនដី ឬអង្គភាពសង្គមស៊ីវិល អាចផ្តល់មតិរិះគន់ ដោយត្រូវដាក់លិខិតក្នុងប្រអប់សំបុត្រនៅតាមសាខាពន្ធដារខេត្ត ឬទីស្នាក់ការប្រមូលពន្ធ ក្នុងករណីពិនិត្យឃើញថាមានការទារពន្ធលើស រឿងភាពមិនច្បាស់លាស់ ឬអំពើវិច្ឆេទកម្ម ដូចជា មានលក់ប័ណ្ណបង់ពន្ធក្លែងក្លាយ ធ្វើឱ្យមានភាពចលាចលដែលនាំឱ្យបាត់បង់ថវិកាជាតិ និងភាពអសកម្មនានាក្នុងការប្រមូលពន្ធ។

### ៣.២.២ ភារកិច្ចភ្នាក់ងារពន្ធដារ

ភ្នាក់ងារពន្ធដារដែលមានកាតព្វកិច្ចប្រមូលពន្ធលើយានជំនិះគ្រប់ប្រភេទ សម្រាប់ប្រចាំឆ្នាំត្រូវអនុវត្តដូចខាងក្រោម៖

- ត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធដារក្នុងម៉ោងធ្វើការ
- ត្រូវមានសីលធម៌ សុភាពរាបសា និងហ្មត់ចត់ក្នុងការងារ

- ត្រូវគោរពម៉ោងការងារឱ្យបានទៀងទាត់ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និងថ្ងៃអាទិត្យតាមសំណូមពររបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងករណីចាំបាច់។
    - ព្រឹក: ពីម៉ោង៨:៣០ ដល់១១: ៣០
    - រសៀល: ពីម៉ោង១៤:០០ ដល់១៦: ៣០
- ដោយហេតុថានៅពេលព្រឹក ត្រូវបើកឯកសារ និងពេលរសៀលត្រូវទូទាត់ប្រាក់ពន្ធដែលប្រមូលបានចូលក្នុងបេឡា។
- នៅតាមប៉ុស្តិ៍ (ទីចំណត) ឬស្នាក់ការពន្ធដារ ភ្នាក់ងាពន្ធដារ សាខាពន្ធដារ ត្រូវតែរៀបចំកន្លែងធ្វើការឱ្យមានស្អាត មានរបៀបរៀបរយ ឱ្យបានសមរម្យ រៀបចំទីកន្លែងឱ្យមានផាសុខភាពល្អ សម្រាប់បុគ្គលិក និងអ្នកទៅទទួលយកឯកសារ សេវាកម្ម និងមានបំពាក់សម្ភារដូចជា៖
    - ចងផ្ទាំងក្រណាត់ទំហំ ០៦ម x ៤ម និងបោះពុម្ពខិត្តប័ណ្ណផ្សាយអំពីព័ត៌មាន ក្នុងយុទ្ធនាការប្រមូលពន្ធលើយានជំនិះគ្រប់ប្រភេទ
    - នៅទីតាំងប្រមូលពន្ធ ត្រូវបិទតារាងតម្លៃប្រាក់ពន្ធ តម្លៃលិខិតប្រកាស និងព័ត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងការប្រមូលពន្ធ ដើម្បីឱ្យម្ចាស់យានជំនិះអនុវត្តឱ្យមានត្រឹមត្រូវតាមច្បាប់កំណត់។
- ភ្នាក់ងារពន្ធដារ មិនត្រូវទារ ឬទទួលប្រាក់លើសពីការលក់ឯកសារ ឬកម្រៃពីការសរសេរបង្កាន់ដៃបង់ពន្ធ ទោះស្ថិតក្នុងរូបភាពណាក៏ដោយ។ ទន្ទឹមនឹងនេះភ្នាក់ងារពន្ធដារ ត្រូវត្រៀមសាច់ប្រាក់តាមប្រភេទដើម្បីទូទាត់ (អាប់) ជូនម្ចាស់យានជំនិះដោយភាពត្រឹមត្រូវ។
- នៅតាមសាខាពន្ធដារខេត្ត និងនៅតាមទីស្នាក់ការពន្ធដារស្រុកនីមួយៗ ភ្នាក់ងារពន្ធដារត្រូវតែរៀបចំប្រអប់សំបុត្រមានចាក់សោ ដើម្បីទទួលព័ត៌មានផ្សេងៗជាយថាហេតុ។ ប្រអប់សំបុត្រនេះ ត្រូវបើកជារៀងរាល់ថ្ងៃ ហើយរាយកាណ៍ជូនប្រធានអង្គភាពសាមី ដើម្បីដោះស្រាយ។

**៣.២.៣ សិទ្ធទទួល និងការប្រើប្រាស់ឯកសារពន្ធ**

ក្រោយពេលបង់ពន្ធរួចហើយ ម្ចាស់យានជំនិះគ្រប់ប្រភេទ ត្រូវទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូនមួយសន្លឹក ចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងលតាបត្រសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយសន្លឹក។ បង្កាន់ដៃទទួលប្រាក់ពន្ធនេះ ត្រូវរក្សាទុកជាប់នឹងយានជំនិះ សម្រាប់ទុកបង្ហាញមន្ត្រីមានសមត្ថកិច្ច និងអាចជាឯកសារសម្រាប់ប្រកាសពន្ធនៅឆ្នាំបន្ទាប់។

**៣.២.៤ ទោសទណ្ឌ ការខកខានមិនបានបង់ពន្ធ និងបញ្ញាប្រឈម**

- **ការត្រួតពិនិត្យ និងទោសទណ្ឌ**

ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ គ្រប់សាខាពន្ធដារខេត្ត ខណ្ឌទាំងអស់ ត្រូវរៀបចំយន្តការត្រួតពិនិត្យការប្រកាសបង់ពន្ធនេះឱ្យបានរួចរាល់ ដូចប្រតិបត្តិការដែលបានអនុវត្តកន្លងមកដែរ។ ទន្ទឹមនឹងនេះ គ្រប់សាខាពន្ធដារខេត្ត ខណ្ឌទាំងអស់ ឬធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារសាធារណៈភីអិលស៊ី ធនាគារវឌ្ឍនៈ...ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តទទួលប្រាក់ពន្ធលើយានជំនិះគ្រប់ប្រភេទ។

ចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំបន្ទាប់ អគ្គនាយកដ្ឋានពន្ធដារ និងចុះត្រួតពិនិត្យអំពីការប្រកាសពន្ធ និងផាកពិន័យចំពោះយានជំនិះទាំងឡាយណាដែលមិនបានប្រកាសបង់ពន្ធ តាមកាលកំណត់ខាងលើនេះ។

នៅគ្រប់សាខាពន្ធដាររាជធានី ខេត្ត ធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារសាធារណៈភីអិលស៊ី ធនាគារវឌ្ឍនៈ...ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីចុះហត្ថលេខាតទៅ។

- **ការខកខាន ឬមិនមានបង់ពន្ធប្រចាំឆ្នាំ**

ចំពោះយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមិនទាន់បានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន នៅក្នុងឆ្នាំកន្លងមក ត្រូវបង់ប្រាក់ពន្ធ និងប្រាក់ពិន័យតាមបណ្តាឆ្នាំទាំងនោះឱ្យរួចរាល់ជាមុនសិន ទើបអនុញ្ញាតឱ្យប្រកាសបង់ពន្ធសម្រាប់ឆ្នាំបច្ចុប្បន្ន។

សម្រាប់យានជំនិះគ្រប់ប្រភេទ ដែលមានប័ណ្ណសម្គាល់យានយន្តចេញលើកដំបូងក្នុងខែធ្នូ ត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទក្នុងឆ្នាំនោះ ដោយលើកលែងប្រាក់ពិន័យ។ ក្នុងករណីប័ណ្ណសម្គាល់យានយន្តចេញចេញលើកដំបូងក្នុងខែធ្នូ និងមានបង្កាន់ដៃបង់ពន្ធនាំចូលចេញ ក្នុងខែធ្នូក្នុងឆ្នាំតែមួយ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធក្នុងឆ្នាំបន្ទាប់។ ការអនុញ្ញាតនេះមិនមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ។ ការអនុញ្ញាតឱ្យប្រកាសពន្ធខាងលើ គឺទទួលស្គាល់តែកាលបរិច្ឆេទនៃបង្កាន់ដៃបង់ពន្ធនាំវូលតែប៉ុណ្ណោះ។

ដើម្បីឱ្យការគ្រប់គ្រង និងការប្រមូលពន្ធលើយានជំនិះគ្រប់ប្រភេទ ប្រចាំឆ្នាំឱ្យមានប្រសិទ្ធភាព រថយន្តដែលបាននាំចូលយកមកដាក់លក់នៅតាមឃ្លាំងនានា ក៏ត្រូវយកមកប្រកាសបង់ពន្ធលើយានជំនិះគ្រប់ប្រភេទ ឱ្យបានទាន់ពេលវេលានៃឆ្នាំប្រមូលពន្ធនេះដែរ ព្រោះថារថយន្តទាំងនេះនាំចូលក្នុងគោលបំណងដាក់ឱ្យចរាចរណ៍ទាំងអស់ លើកលែងតែរថយន្តបានដាក់លក់នៅតាមឃ្លាំង និងតាមក្រុមហ៊ុន ឬសាខាក្រុមហ៊ុន ដែលបានប្រកាសជាសន្និធិរបស់ឃ្លាំង ឬសាខាក្រុមហ៊ុន ដែលមានសកម្មភាពទិញ-លក់។

**៣.២.៥ ការប្រកាសពន្ធ**

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ម្ចាស់យានជំនិះត្រូវភ្ជាប់មកជាមួយនូវៈ

- ✓ ចំពោះម្ចាស់យានជំនិះដែលមានប័ណ្ណសម្គាល់ការបង់ពន្ធ

  ប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមិនចាំដាក់លិខិតប្រកាសពន្ធ។ ករណីបាត់ប័ណ្ណនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំបោះពុម្ពប័ណ្ណបង់ពន្ធសារជាថ្មី។ នៅសាខាពន្ធដារខេត្ត ខណ្ឌ ឬនៅសាខាណាមួយនៃធនាគារខាងលើ ដោយត្រូវបង់កម្រៃសេវាក្នុងការធ្វើប័ណ្ណនេះចំនួន៥០០០រៀល

- ✓ ចំពោះយានយន្តគ្រប់ប្រភេទដែលទើបមកប្រកាសពន្ធ

  ម្ចាស់យានយន្តគ្រប់ប្រភេទត្រូវបំពេញ និងដាក់លិខិតប្រកាសពន្ធចំនួន០២សន្លឹក តាមទម្រង់ដែលបានចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយឯកសារបង់ពន្ធប្រចាំឆ្នាំ ឬឆ្នាំកន្លងមក។

ករណីបាត់បង់ឯកសារនេះ ម្ចាស់យានយន្តទៅដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំកន្លងមក នៅសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីប្រើប្រាស់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ធ្វើបច្ចុប្បន្ន។

✓ ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបប្រកាសពន្ធលើកដំបូង

ម្ចាស់យានយន្តគ្រប់ប្រភេទត្រូវបំពេញ និងដាក់លិខិតប្រកាសពន្ធចំនួន០២សន្លឹក តាមទម្រង់ដែលបានចេញដោយអគ្គនាយកដ្ឋានពន្ធដារ និងភ្ជាប់មកជាមួយឯកសារដូចខាងក្រោម៖

- ប័ណ្ណសម្គាល់យានយន្ត ឬវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- បង្កាន់ដៃបង់ពន្ធនាំចូល ឬលិខិតបញ្ជាក់ការប្រើប្រាស់ ចេញដោយឃុំសង្កាត់ ចំពោះយានយន្តកែច្នៃក្នុងស្រុក និងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ ឬលិខិតឆ្លងដែន លិខិតបញ្ជាក់សំបុត្រកំណើត ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋាន។

✓ ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលបានបង់ពន្ធឆ្នាំកន្លងមក ហើយត្រូវមកប្តូរប័ណ្ណសម្គាល់យានយន្តថ្មី

ម្ចាស់យានយន្តធ្វើបច្ចុប្បន្នភាព ព័ត៌មានយានយន្តដើម្បីប្រកាសបង់ពន្ធ និងប្តូរប័ណ្ណសម្គាល់ការបង់ពន្ធ ក្នុងករណីរថយន្តនោះប្តូរផ្លាកលេខ។ ដើម្បីមានភាពងាយស្រួលក្នុងការប្រើប្រាស់ការបង់ពន្ធប្រភេទនេះ នៅឆ្នាំបន្តបន្ទាប់ខាងមុខ ម្ចាស់យានយន្តអាចស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយគ្រាន់តែគូសក្នុងប្រអប់ដែលមានបង្ហាញក្នុងលិខិតប្រកាសពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ។ ការស្នើសុំនេះត្រូវបង់ថ្លៃសេវាចំនួន៥០០០រៀល។






## ៣.៣ ប្រភេទយានជំនិះដែលអគ្គនាយកដ្ឋានពន្ធដារ កំណត់ឱ្យជាប់ពន្ធ

ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់តាមប្រភេទនីមួយៗដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ដែលរួមមាន៖

- **រថយន្តទេសចរណ៍** គឺគិតតាមទំហំស៊ីឡាំងជា ស.ម³ មានដល់១៥០០ស.ម³ លើសពី១៥០០ស.ម³ ដល់២០០០ស.ម³ លើសពី២០០០ស.ម³ ដល់២៩០០ស.ម³ លើសពី២៩០០ស.ម³ ដល់៤០០០ស.ម³ និងលើសពី៤០០០ស.ម³ ឡើងទៅ ដោយគិតពីឆ្នាំផលិតដល់៥ឆ្នាំ និងលើសពី១០ឆ្នាំ។ ដោយឡែកចំពោះរថយន្តដឹកទំនិញធន់តូច ដែលមានទ្វារបួន (PICK UP) អាយុកាលគិតពីឆ្នាំផលិតផលដល់៥ឆ្នាំ និងរថយន្តដឹកអ្នកដំណើរ ដែលមានអាយុកាលគិតពីឆ្នាំផលិត ដល់៥ឆ្នាំ ត្រូវចាត់ទុកជារថយន្តទេសចរណ៍ ដែលត្រូវបង់តាមទំហំស៊ីឡាំង និងឆ្នាំផលិត ដូចរថយន្តទេសចរណ៍ដទៃទៀតដែរ។
- **រថយន្តដឹកទំនិញ** គឺត្រូវបានគិតពន្ធទៅតាមប្រភេទនីមួយៗ និងទៅតាមការកែច្នៃរថយន្តដូចខាងក្រោម
  - គិតតាមទម្ងន់សរុប មានទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)មានដល់បីតោន លើពីបីតោន ដល់ដប់តោន លើសពីដប់តោន ទៅម្ភៃតោន និងលើសពីម្ភៃតោន
  - គិតតាមចំនួនភ្លៅ និងកង ចំពោះរថយន្តកែច្នៃផ្សេងទៀត ក្នុងរថយន្តមានភ្លៅ
  - រថយន្តដែលមានភ្លៅបី និងកង់ប្រាំមួយ ត្រូវបង់ពន្ធដូចរថយន្តដឹកទំនិញលើសពីដប់តោន ដល់ម្ភៃតោន
  - រថយន្តដែលមានភ្លៅបី និងកង់ដប់ ត្រូវបង់ពន្ធដូចរថយន្តដឹកទំនិញលើសពីម្ភៃតោន
  - រថយន្តកែច្នៃ (គោយន្ត និងរថយន្តកងបី ដែលបំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវបង់ពន្ធដូចរថយន្តដឹកទំនិញដល់បីតោន
  - រថយន្តជាក្បាលសណ្តោងរ៉ឺម៉ក ត្រូវបង់ពន្ធរួមគ្នា គិតទាំងទម្ងន់ក្បាលរថយន្តសណ្តោងទម្ងន់ រ៉ឺម៉ក និងទម្ងន់ផ្ទុក ត្រូវបង់ពន្ធដូចរថយន្តដឹកទំនិញលើសពីម្ភៃតោន។
- **រ៉ឺម៉កសណ្តោង** គិតពន្ធទៅតាមទម្ងន់រ៉ឺម៉ក ទម្ងន់មនុស្ស ទៅតាមភ្លៅនិងកង់ និងការកែច្នៃរ៉ឺម៉កដូចខាងក្រោម៖
  - គិតតាមទម្ងន់សរុប ដែលមានទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក មានចាប់ពីបីតោន ដល់១០តោន លើសពីដប់តោន ដល់ម្ភៃតោន និងលើសពីម្ភៃតោន
  - តាមចំនួនភ្លៅ និងកង់ ចំពោះរ៉ឺម៉កកែច្នៃ ក្នុងនោះមានភ្លៅពីរ កង់បួន បង់ពន្ធដូចរថយន្តដឹកទំនិញបីតោន ភ្លៅពីរ កង់ប្រាំបី បង់ពន្ធដូចរ៉ឺម៉ងសណ្តោង ដែលមានទម្ងន់ចាប់ពីបីតោន ដល់ដប់តោន។
- **រថយន្តដឹកអ្នកដំណើរ**

  គិតពន្ធទៅតាមចំនួនកៅអី មានកៅអីដល់ដប់ប្រាំ មានកៅអីដល់ដប់ប្រាំមួយ មានកៅអីដល់ម្ភៃប្រាំ និងមានកៅអីលើសពីម្ភៃប្រាំ។
- **ជលយាន ឬជលយានយន្តផ្លូវទន្លេ**

គិតពន្ធទៅតាមការដឹកទំនិញ ដឹកអ្នកដំណើរ ការសណ្ដោង និងការនេសាទ ដូចខាងក្រោម៖

- ដឹកទំនិញ គិតតាមទម្ងន់ផ្ទុក មានដល់បីតោន លើសពីបីតោន ដល់ដប់តោន លើសពីដប់តោន ដល់ម្ភៃតោន និងលើសពីម្ភៃតោន។
- ដឹកអ្នកដំណើរ គិតជាប្រវែងបណ្ដោយ មានដល់ម្ភៃម៉ែត្រ លើសពីម្ភៃម៉ែត្រ ដល់សាបសិបម៉ែត្រ និងលើសពីសាបសិបម៉ែត្រឡើង។
- សណ្ដោង គិតជាកម្លាំងសេស លើសពី១៥០ ដល់២០០សេស លើសពី២០០សេស ដល់២៥០សេស និងលើសពី២៥០សេសឡើងទៅ។
- នេសាទ គិតជាកម្លាំងសេស លើសពី១៥០ ដល់២០០សេស លើសពី២០០សេស ដល់២៥០សេស និងលើសពី២៥០សេសឡើងទៅ។

- **ជលយាន ឬជលយានយន្តផ្លូវសមុទ្រ**

គិតពន្ធទៅតាមការដឹកទំនិញ ដឹកអ្នកដំណើរ ការសណ្ដោង និងការនេសាទ ដូចខាងក្រោម៖

- ដឹកទំនិញ គិតតាមទម្ងន់ផ្ទុក មានដល់១០០តោន លើសពី១០០តោន ដល់១០០០តោន លើសពី១០០០តោន ដល់២០០០តោន និងលើសពី២០០០តោន។
- ដឹកអ្នកដំណើរ គិតជាប្រវែងបណ្ដោយ មានដល់ម្ភៃម៉ែត្រ និងពីម្ភៃមួយម៉ែត្រ ដល់សាបសិបម៉ែត្រ។
- នេសាទ គិតជាកម្លាំងសេស (ទូកមានកម្លាំងលើសពី១៥០សេសឡើងទៅ កប៉ាល់មានកម្លាំងលើសពី១៥០ ដល់២០០សេស លើសពី២៥០ ដល់៥០០សេស និងលើសពី៥០០សេសឡើងទៅ សណ្ដោង គិតជាកម្លាំងសេស កប៉ាល់មានកម្លាំងលើសពី១៥០សេស ដល់៥០០សេស និងលើសពី៥០០សេសឡើងទៅ)។

- **អូប័រផ្លូវទន្លេ ឬសមុទ្រ**

គិតជាកម្លាំងសេស អូប័រមានកម្លាំងលើសពី១៥០សេស ដល់២០០សេស និងលើសពី២០០សេសឡើងទៅ។



# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្នុងនាមខ្ញុំជានិស្សិតសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលសរសេរស្តីពី «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ**» បានមើលឃើញថាពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទនេះ គឺជាប្រភេទពន្ធមួយ ក្នុងប្រភេទពន្ធជាច្រើនដែលពិតជាមានសារៈសំខាន់ណាស់ ក្នុងការកៀរគរចំណូលដែលជាប្រយោជន៍ដល់ថវិកាជាតិ។ ហេតុដូចនេះទើបមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

យោងតាមការសិក្សាកន្លងមក នាងខ្ញុំសង្កេតឃើញថា «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ**» របស់អគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់ ដោយសារតែមូលហេតុមួយចំនួនដូចជា៖

- អគ្គនាយកដ្ឋានពន្ធដារ បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយធនាគារដែលជាដៃគូរសហការដូចជា ធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារសាធារណៈភីអិលស៊ី ធនាគារវឌ្ឍនៈ គ្រប់សាខាពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់ភាពងាយស្រួលដល់ការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ។
- ប្រព័ន្ធបង់ពន្ធតាមអនឡាញ (E-tax services) អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍប្រព័ន្ធបង់ពន្ធតាមអនឡាញ ឱ្យម្ចាស់យានជំនិះអាចបង់ពន្ធបានងាយស្រួល ដោយមិនចាំបាច់ទៅដល់កន្លែងទីស្នាក់ការជាតិ។
- ភាពច្បាស់លាស់នៃអត្រាពន្ធ តារាងពន្ធលើយានជំនិះត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ ដោយផ្អែកលើប្រភេទម៉ូតូ ឬរថយន្ត ទំហំម៉ាស៊ីន ឆ្នាំផលិត និងតម្លៃផ្សារ។
- ភាពសហការណ៍ជាមួយក្រសួងដទៃ ជាពិសេសជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន (ពាក់ពន្ធ័នឹងការចុះបញ្ជីយានជំនិះ) ធ្វើឱ្យការបញ្ជាក់ម្ចាស់យានជំនិះ និងទិន្នន័យមានភាពត្រឹមត្រូវ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ នាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យ «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ**» កាន់តែប្រសើរឡើងដូចជា៖

- ភាពមិនស្មើគ្នានៃការអនុវត្តច្បាប់ម្ចាស់យានជំនិះខ្លះអាចជៀសវាងការបង់ពន្ធបានដោយមិនទទួលការចាត់វិធានណាមួយ បណ្តាលឱ្យមានភាពមិនយុត្តិធម៌។
- ការផ្សព្វផ្សាយអប់រំពលរដ្ឋមិនទាន់គ្របដណ្តប់ទូលំទូលាយ ម្ចាស់យានជំនិះជាច្រើននៅតែមិនយល់ពីសិទ្ធិកាតព្វកិច្ចពន្ធ ដោយសារខ្វះការផ្សព្វផ្សាយផ្លូវការ ឬត្រឹមត្រូវ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្នុងនាមនាងខ្ញុំជានិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលសរសេរបាយការណ៍ស្រាវជ្រាវស្តីពី«**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ**» បានមើលឃើញថាពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទនេះ គឺជាប្រភេទពន្ធមួយ ក្នុងប្រភេទពន្ធជាច្រើនដែលពិតជាមានសារៈសំខាន់ណាស់ ក្នុងការកៀរគរចំណូលដែលជាប្រយោជន៍ដល់ថវិកាជាតិ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារ មិនបានធ្វើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន តាមផ្លូវអាកាស និងផ្លូវដែកទេ ជាបញ្ហាមួយចំនួនដែលត្រូវលើកឡើងខាងលើ។ ជាការពិតណាស់ ការដែលអគ្គនាយកដ្ឋានពន្ធដារមិនបានយកពន្ធលើមធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស និងផ្លូវដែក ដែលជាហេតុធ្វើឱ្យរដ្ឋាភិបាលបាត់ចង់ចំណូលមួយផ្នែក ហើយធ្វើឱ្យមិនមានតម្លាភាពដល់អ្នកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹកផងដែរ។ បើសិនជារដ្ឋាភិបាលបានអនុម័តច្បាប់នេះចូលជាធរមាន នោះវាពិតជាទទួលបានប្រភពចំណូលមួយផ្នែកទៀត សម្រាប់ការអភិវឌ្ឍន៍ប្រទេសទាំងមូលផងដែរ។ ដូចគ្នានេះដែរ បញ្ហាអ្នកបង់យឺត និងអ្នកគេចវេសក្នុងការបង់ពន្ធ ក៏ជាបញ្ហាមួយរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលពិបាកគ្រប់គ្រង និងប្រមូលពន្ធឱ្យបានទាន់ពេលវេលាដែលបានកំណត់ និងមានប្រសិទ្ធភាពខ្ពស់ផងដែរ។

ដូចនេះក្នុងនាមជាប្រជាពលរដ្ឋទាំងអស់ ដែលមានការជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ពន្ធដោយស្ម័គ្រចិត្ត និងស្មោះត្រង់ឱ្យទាន់ពេលវេលា និងចូលរួមសហការជាមួយភ្នាក់ងារពន្ធដារ ក្នុងការអនុវត្តច្បាស់ និងបទប្បញ្ញត្តផ្សេងៗ ស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ឱ្យមានតម្លាភាព និងប្រសិទ្ធភាព។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ស្តីពី «**កាតព្វកិច្ចនៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ**» មានវិវឌ្ឍភាពយ៉ាងខ្លាំងក្លា តាំងពីចាប់ផ្តើមរហូតមកដល់បច្ចុប្បន្នភាព ដែលសារពើពន្ធមានការកើនឡើងលើសពីផែនការកំណត់ជារៀងរាល់ឆ្នាំ។

ថ្វីបើយុទ្ធសាស្ត្រដែលកំពុងអនុវត្តន៍ដូចជា យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម មានប្រសិទ្ធភាពមែនពិត ប៉ុន្តែដោយបរិការណ៍នៃសេដ្ឋកិច្ច និងតម្រូវការនៃការអភិវឌ្ឍប្រទេសជាតិខ្ពស់ រដ្ឋាភិបាលគួរតែដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត។ ដូចនេះគួរតែមានការបង្កើតប្រភេទពន្ធបន្ថែម ដូចជាពន្ធលើផលប៉ះពាល់បរិស្ថានជាដើម ដែលជាកត្តាមួយធ្វើឱ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចរបស់ជាតិ ហើយអនុវត្តចំពោះបុគ្គលដែលធ្វើឱ្យប្រទេសមានភាពកង្វក់ អាចជាការបំពុលខ្យល់ បំពុលទឹក ឬផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់បរិយាកាសធម្មជាតិ។ ចំពោះអត្រាពន្ធវិញ ក៏គួរតែមានចំនួនទ្វេរដង ដើម្បីឱ្យបុគ្គលទាំងនេះមានការរាងចាល និងភ្ញាក់រំលឹកពីកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួនចំពោះមនុស្សជុំវិញ។

ចំណែកឯការបង់ពន្ធយឺត និងការគេចវេសមិនព្រមបង់ ដែលធ្វើឱ្យមានការរាំងស្ទះដល់ការប្រមូលពន្ធ ក្នុងនាមជាអាជ្ញាធរដែលគ្រប់គ្រងលើការប្រមូលពន្ធនេះ គួរតែអនុម័តច្បាប់ថ្មីដើម្បីគ្រប់គ្រង និងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន តាមផ្លូវដែក និងផ្លូវអាកាសបន្ថែមទៀត ដើម្បីបង្កើនចំណូលជូនជាតិ។

ដើម្បីឱ្យការបង់ពន្ធមានសុចរិតភាព តម្លាភាព និងភាពត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារ រួមទាំងមន្ត្រីពាក់ព័ន្ធ ត្រូវមាននីតិវិធីបន្ថែមដូចជា៖

- អគ្គនាយកដ្ឋានពន្ធដារ គួរតែរឹតបន្តឹងទៅលើការអនុវត្តច្បាប់ នៃការបង់ពន្ធរបស់ម្ចាស់យានជំនិះគ្រប់ប្រភេទ ដើម្បីជៀសវាងភាពមិនស្មើគ្នារបស់អ្នកបង់ពន្ធ។
- អគ្គនាយកដ្ឋានពន្ធដារគួរធ្វើការផ្សព្វផ្សាយអប់រំនិងបណ្តុះបណ្តាលបន្ថែមទៀតដល់ប្រជាពលរដ្ឋដែលមិនទាន់យល់ច្បាស់ពីកាតព្វកិច្ចនៃការបង់ពន្ធលើយានជំនិះ។

# ឯកសារយោង

# ឯកសារយោង


- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០,នស/រកម/០១៩ធ្នូ២០១៧,មាត្រា៥៧ថ្មី(ពីរ)។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧,លេខ នស/រកម/១២១៥/០១៦, ១៧ ធ្នូ ១០១៥, មាត្រា២៦ថ្មី(មួយ)។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦,លេខ នស/រកម/១២១៥/០១៦, ១៧ ធ្នូ ២០១៥, មាត្រា១២
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៥, នស/រកម/១២០៤/០០២, ៣០ ធ្នូ ២០០៤, មាត្រា៨
- ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, នស/រកម/០២៨៧/០៣ ២៤ កុម្ភៈ ១៩៩៧ មាត្រា ១២៥-១៣៣
- ៦.អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម, លេខ ១១៤ អនក្រ/បក, ២៤ ធ្នូ ១៩៩៩, មាត្រា ៤៩ប្រកាសស្តីពីការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ, លេខ ៣៦១ សហវ.ប្រក, ៣ មេសា ២០១៨។
- ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ០២៥ សហវ. ប្រក . អពដ,២៤ មករា ២០១៨។
- ប្រកាសស្តីពីការណែនាំអនុវត្តន៍អាករលើតម្លៃបន្ថែម ចំពោះការផ្គត់ផ្គង់មិនជាប់អាករ, លេង៥៥៩ សហវ ប្រ.ក, ២៤ ឧសភា ២០១៧។
- ប្រកាសស្តីពីការកែតម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ,លេខ ១៥៣៩ សហវ ប្រ.ក, ២៣ ធ្នូ ២០១៦។
- ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់អង្ករសម្រាប់បម្រើឲ្យការនាំចេញអង្ករ, លេខ ៣១៣ សហវ. ប្រក, ១៩ មីនា ២០១៤។
- ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឲ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងការបូបដៃ និងឧស្សាហកម្មផលិតមួក ,លេខ ៣១១ សហវ. ប្រក, ១៩ មីនា២០១៤។
- ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ ១១៧៣ សហវ. ប្រ.ក, ៣១ ធ្នូ ២០០៣។
- ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ ១១៧៣ សហវព. ប្រ.ក, ៣១ ធ្នូ ២០០៣, ជំពូកទី៣។
- ប្រកាសស្តីពីពន្ធលប្រាក់ចំណេញ, លេខ ១០៥៩ សហវ. ប្រក.ពដ, ១២ ធ្នូ ២០០៣។
- ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ, លេខ ១៧៥ សហវ. ពដ. ប្រក,២២ មករា ២០០២។
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, «សៀវភៅណែនាំស្តីពីពន្ធកាត់ទុកលើនិវាសនជន និងអនិវាសនជន» ២០១៣។
- អនុបណ្ឌិត ហាយ ចំរើន សាស្ត្រាចារ្យនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង, «ពន្ធដារ», ២០១០។
- នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «សិទ្ធិ និងកាតព្វកិច្ចអ្នកជាប់ពន្ធ», ១០១០។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ


ការចូលរួមចំណែកនៃចំណូលពន្ធផ្ទៃក្នុងសម្រាប់ការអភិវឌ្ឍជាតិ
បើកប្រាក់ខែជូនមន្ត្រីរាជការ
For paying salary for civil servants
សាងសង់មន្ទីរពេទ្យ
For building hospitals
បើកប្រាក់ខែជូនកងទ័ព និងកម្លាំងប្រដាប់អាវុធ
For paying salary for soldiers and armed forces
ចំណូលពីពន្ធដារ
TAXES
សាងសង់ផ្លូវ
For building roads
សាងសង់ស្ពាន
For building bridges
ការពារព្រំដែន
For defending borders & heritages
សាងសង់សាលារៀន
For building schools


កំណើនផែនការប្រមូលចំណូលរបស់ អពដ និង អគរ ២០១៤ ដល់ ២០២០
ភាគរយ
30.0%
25.0%
20.0%
15.0%
10.0%
5.0%
0.0%
2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020
អពដ | 14.8% | 17.2% | 22.0% | 20.7% | 12.1% | 19.0% | 26.0%
អគរ | 14.0% | 13.8% | 26.1% | 10.0% | 14.0% | 9.2%


២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ (២០១៩-២០២៣)
យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤
(Rectangular Strategy Phase4)
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
(PFMRP)
យុទ្ធសាស្ត្រប្រមូលចំណូល ២០១៩-២០២៣
(RMS)
ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ
(SP & OP)
គោលបំណងជាយុទ្ធសាស្ត្រ៖
➢ គោលបំណងទី១៖ បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព
➢ គោលបំណងទី២៖ បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ
➢ គោលបំណងទី៣៖ អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយ
អភិបាលកិច្ចល្អ
(Good Governance)
រដ្ឋបាលកិច្ចល្អ
(Good Administration)
ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ
(Effective Leadership & Management)
គុណាធិបតេយ្យ
(Meritocracy)


២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ
(១) តម្លាភាព
(Transparency)
(២) គណនេយ្យភាព
(Accountability)
(៣) ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
(Effectiveness and Efficiency)
(Participation)
(៥) នីតិរដ្ឋ
(Rule of law)
(៦) សមធម៌ និងបរិយាប័ន្ន
(Equity and Inclusiveness)
(Consensus orientated)
(Responsiveness)
អភិបាលកិច្ចល្អ
(Good Governance)

## ២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ

### គំរូនៃការពង្រឹងអភិបាលកិច្ចល្អនៃអគ្គនាយកដ្ឋានពន្ធដារ














## ៣- លទ្ធផលនៃកំណែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ
### ប្រភេទពន្ធ និងអាករផ្សេងៗ

1. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល (1%)
2. ពន្ធអប្បបរមា (1%)
3. អាករពិសេសលើទំនិញ និងសេវាមួយចំនួន (35% ស្រា 30% ស្រាបៀរ, 20% បារី, សំបុត្រយន្តហោះ 10%, ទូរគមនាគមន៍ 3%)
3. អាករបំភ្លឺសាធារណៈ (3%)
4. អាករលើការស្នាក់នៅ (2%)
5. ពន្ធកាត់ទុក (ការជួល 10%, សេវាកម្ម និង Royalties 15%, ការប្រាក់ 15% (កម្ចីក្នុងស្រុក), ការប្រាក់ 4% ឬ 6% (ស្ថាប័នហិរញ្ញវត្ថុ))
6. ពន្ធលើប្រាក់ចំណូល (20%)
7. ពន្ធប៉ាតង់ (តូច- 100$, មធ្យម- 300$, ធំ 750$ ឬ 1,250$)
8. ពន្ធលើស្លាកយីហោ
9. អាករលើតម្លៃបន្ថែម (10%)
10. ពន្ធលើប្រាក់បៀវត្ស (0% ដល់ 20%)
11. ពន្ធលើអចលនទ្រព្យ (0.1%)
12. ពន្ធលើដីធ្លីមិនបានប្រើប្រាស់ (2%)
13. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
14. ពន្ធប្រថាប់ត្រា
    - ៤% លើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (ប្រកាសកំណត់តម្លៃអចលនទ្រព្យ)
    - 0.១% លើតម្លៃភាគហ៊ុន ឬតម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញសេវាប្រើប្រាស់ថវិការដ្ឋ
    - ២៥០$ ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ ប្រភេទ (លិខិតស្តីពីការបង្កើតក្រុមហ៊ុន, បិទក្រុមហ៊ុន និងរំលាយក្រុមហ៊ុន)